ក

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៨-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣៥ ស្តីពី ការតែងតាំងមន្ត្រីរាជការថ្នាក់អគ្គនាយក ចំនួន ០២ រូប នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ | ៦៦៤៧ |
| ២២-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣៦ ស្តីពី ការកាត់ផ្ទៃដីទំហំ ៩៣០៦ ហិកតា នៅស្រុកបុទុមសាគរ និងស្រុកគីរីសាគរ ខេត្តកោះកុង ពីដីឧទ្យានជាតិបុទុមសាគរ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៥ | ៦៦៤៨ |
| ២៨-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៤០ ស្តីពី ការតម្លើងថ្នាក់ ជាករណីពិសេស ដល់លោក **ជា តារា** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៦៦៤៩ |
| ២៨-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៤១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក និងលោកស្រី ចំនួន ០៦ រូប | ៦៦៥០ |
| ២៨-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៤២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោកជំទាវ **ប៊ូ ជាំងគួ** (BU Jianguo) | ៦៦៥១ |
| ២៨-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៤៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម Gao Hucheng | ៦៦៥២ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ២៧-៧-២០១៦ | -អនុក្រឹត្យលេខ ១៥៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៩៣០៦ ហិកតា នៅស្រុកបុទុមសាគរ និងស្រុកគីរីសាគរ ខេត្តកោះកុង ចេញពីដីឧទ្យានជាតិបុទុមសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ | ៦៦៥៣ |

| | | |
|---|---|---|
| ២៩-៧-២០១៦ | -អនុក្រឹត្យលេខ ១៦០ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា | ៦៦៥៦ |
| ២៨-៧-២០១៦ | -អនុក្រឹត្យលេខ ៨២៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៦៦៦៧ |
| ២៨-៧-២០១៦ | -អនុក្រឹត្យលេខ ៨២៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៦៦៦៨ |
| ២៩-៧-២០១៦ | -អនុក្រឹត្យលេខ ៨២៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៦៦៦៩ |
| ២៩-៧-២០១៦ | -អនុក្រឹត្យលេខ ៨៣០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ | ៦៦៧១ |
| ០១-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី | ៦៦៧៣ |
| ០១-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣២ អនក្រ.តត ស្តីពី ការផ្ទេរយោធិនពិការ | ៦៦៧៤ |
| ០១-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៦៦៧៦ |
| ០១-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៦៦៧៧ |
| ០២-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៦៦៨២ |
| ០២-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៦៦៨៣ |
| ០២-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស សហមេត្រី | ៦៦៨៥ |
| ០២-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣៨ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង សម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិ ស្តីពី មុខរបរ និងការងារ ឆ្នាំ ២០១៥-២០២៥ | ៦៦៨៧ |
| ០២-៨-២០១៦ | -អនុក្រឹត្យលេខ ៨៣៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៦៦៩១ |


## ២‿សេចក្តីសម្រេច


| | | |
|---|---|---|
| ២១-៧-២០១៦ | -សេចក្តីសម្រេចលេខ ៧២ សសរ ស្តីពី ការជ្រើសរើសពលទាហាន | ៦៧០១ |
| ០១-៨-២០១៦ | -សេចក្តីសម្រេចលេខ ៧៥ សសរ ស្តីពី ការផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា | ៦៧០២ |
| ០២-៨-២០១៦ | -សេចក្តីសម្រេចលេខ ៧៦ សសរ ស្តីពី ការតែងតាំងប្រធាន និងអនុប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា | ៦៧០៤ |

## III-ការងារបណ្ណាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០៤-៧-២០១៦ -ប្រកាសលេខ ៧៦១ សហវ.ប្រក ស្តីពី ការបង្កើតគណៈកម្មការចំណាត់ថ្នាក់ សម្រាប់វាយតម្លៃការតម្លើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦៧០៦

២១-៧-២០១៦ -ប្រកាសលេខ ៨៧៤ សហវ.ប្រក ស្តីពី ការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា ៦៧០៨


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ


០៥-០៥-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រក ស្តីពី យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ៦៧១០

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមន្ត្រីរាជការថ្នាក់អគ្គនាយក ចំនួន ០២ រូប នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដូចខាងក្រោម :

១- ឯកឧត្តម **ចាន់ សុទាធូនា** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេស

២- ឯកឧត្តម **ម៉េង ផល្លា** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ច ។

**មាត្រា២ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣៧៧. ១៦០៧. ៧៤៨

លេខៈ ៧៣៩ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** កាត់ផ្ទៃដីទំហំ **៩ ៣០៦** ហិកតា នៅស្រុកបុទុមសាគរ និងស្រុកគិរីសាគរ ខេត្តកោះកុង ពីដីឧទ្យានជាតិបុទុមសាគរ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៥ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរស.១៦០៧.៧៤៥

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៧៣៥ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរារដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សម្ពោហតាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ  នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងថ្នាក់ ជាករណីពិសេសដល់លោក **ជា  តារា** ពីឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៥ មកឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន  សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម  និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរស.១៦០៧.៧៤៩

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៧៤០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦)

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- លោក **គូច ឈួនសៅរ័ត្ន** ២- លោក **អ៊ុត គ្លីង**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- លោកស្រី **ហូ ដានី** ២- លោក **ទៀង សុម៉ាន់**

៣- លោក **រស់ វិសិដ្ឋ** ៤- លោកស្រី **សេង សុរ័ត្ន**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

ព.រ.ល.១៦០៧.៧៥០

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខៈ ៩៧១៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៨៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សម្ពោហភាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន  សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ )

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស  **សហមេត្រី**  ថ្នាក់  **មហាសេនា :**

លោកជំទាវ **ប៊ូ  ជាំងគូ** **( BU Jianguo)**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម  និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

*៣៤៧.១៦០៧.៧៥១*

លេខៈ ៧៣៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ )

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

ឯកឧត្តម **Gao Hucheng**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

៣៧៧.១៦០៧.៧៥៤

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខៈ ៧៣៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៩ ៣០៦ ហិកតា នៅស្រុកបុទុមសាគរ និងស្រុកគិរីសាគរ ខេត្តកោះកុង ចេញពីដីឧទ្យានជាតិបុទុមសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៤១៤ សល ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ របស់គណៈកម្មការអន្តរក្រសួង និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង
- លិខិតលេខ ៦៥២ សជណ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ របស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ៩ ៣០៦ ហិកតា ចេញពីដីឧទ្យានជាតិបុទុមសាគរ ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៧១៦/៧៣៦ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP Co., Ltd និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកបុទុមសាគរ និងស្រុកគិរីសាគរ ខេត្តកោះកុង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មការអន្តរក្រសួង និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនិងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP Co., Ltd នៅស្រុកបុទុមសាគរ និងស្រុកគិរីសាគរ ខេត្តកោះកុង ។

**មាត្រា ៣** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មការអន្តរក្រសួង និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៦០ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការ ត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.ត.ផ.ហា.ក.** ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ក្នុងគោលបំណងលើកកម្ពស់បច្ចេកទេសស្តង់ដារ អនាម័យ និងជំនឿទុកចិត្តពីសាសនិកឥស្លាម មកលើផលិតផលហាឡាលកម្ពុជា សម្រាប់ផ្គត់ផ្គង់ដល់ទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា និងជំរុញការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

**មាត្រា ២.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- "**ហាឡាល**" ឬ "HALAL" ឬ "حلال" (ជាភាសាអារ៉ាប់) សំដៅដល់វត្ថុណាមួយ ឬសេវាកម្មណាមួយ ដែលអនុញ្ញាតឲ្យប្រើប្រាស់ ឬឲ្យចូលរួម ដោយអាស្រ័យទៅតាមច្បាប់ឥស្លាម។ ពាក្យនេះត្រូវបានប្រើជាទូទៅ ទាក់ទងទៅនឹងផលិតផលម្ហូបអាហារ ផលិតផលសាច់ គ្រឿងសម្អាង ផលិតផលថែរក្សាខ្លួន ឱសថ អាហារបំប៉ន គ្រឿងផ្សំម្ហូបអាហារ និងសម្ភារប្រើប្រាស់ផ្សេងៗទៀត។
- **ផលិតផល** សំដៅដល់ប្រភេទទូទៅនៃមុខទំនិញជាគ្រឿងឧបភោគ បរិភោគ និងសេវាកម្ម ដោយបំពេញបាននូវចំណង់ចំណូលចិត្ត ឬសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់។
- **ផលិតផលហាឡាល** សំដៅដល់ផលិតផលដែលកើតឡើងដោយខ្លួនឯង តាមធម្មជាតិ ឬត្រូវបានផលិតឡើង តាមបច្ចេកទេសស្តង់ដារនៃផលិតផលហាឡាល ដែលមិនផ្ទុយនឹងបញ្ញត្តិរបស់សាសនាឥស្លាម។
- **ផលិតផលហាឡាលកម្ពុជា** សំដៅដល់សេវាកម្ម ការផលិត និងការវេចខ្ចប់ ផលិតផលហាឡាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **សេវាកម្ម** សំដៅដល់ការទទួលធ្វើ ការផ្តល់សិទ្ធិ ឬការអនុញ្ញាតឲ្យប្រើ ឬឲ្យផលចំណេញជាទ្រព្យ ឬកិច្ចការណាមួយទៀត ដោយការហៅរកភាគលាភ ឬផលប្រយោជន៍ផ្សេងទៀត ប៉ុន្តែមិនរាប់បញ្ចូល ការរើសបុគ្គលិកតាមច្បាប់ការងារឡើយ។
- **ការផលិត** សំដៅដល់ការកែច្នៃ លាយ ផ្សំ តម្លើង បង្កើត ឬការប្រែរូបភាព និងមានន័យសរុប ទាំងការប្តូរទ្រង់ទ្រាយ ការកែកុនទ្រង់ទ្រាយ ការចែកចាយ ការវេចខ្ចប់ ឬការរក្សាទុក។
- **ការវេចខ្ចប់** សំដៅដល់ការយកផលិតផលហាឡាលសម្រេចមកវេចខ្ចប់ ស្របតាមបច្ចេកទេសស្តង់ដារនៃផលិតផលហាឡាលកម្ពុជា។
- **ចាងហ្វាង នៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា** សំដៅដល់ចាងហ្វាងនៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា ដែលត្រូវបានត្រាស់បង្គាប់តែងតាំងដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## សមាសភាពរបស់ គ.ត.ផ.ហ.ក.

**មាត្រា ៣.-**

**គ.ត.ផ.ហ.ក.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | | ជាប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ០១រូប | ជាអនុប្រធាន |
| - ឥស្សរជន ឥស្លាមជាន់ខ្ពស់ | ០១រូប | ជាអនុប្រធាន |
| - សមាជិក ក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងមហាផ្ទៃ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងយុត្តិធម៌ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងធម្មការ និងសាសនា | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងសុខាភិបាល | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងទេសចរណ៍ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងព័ត៌មាន | ០១រូប | ជាសមាជិក |
| - អគ្គនាយកកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម | | ជាសមាជិក |
| - តំណាង គណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា | ០១រូប | ជាសមាជិក។ |

សមាសភាពជាក់ស្តែង ត្រូវតែងតាំងដោយសេចក្តីសម្រេច របស់រាជរដ្ឋាភិបាល។

## ជំពូកទី ៣
## តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ គ.ត.ផ.ហ.ក.

**មាត្រា ៤.-**

**គ.ត.ផ.ហ.ក.** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើការសិក្សាស្រាវជ្រាវ រៀបចំ និងចងក្រងឯកសារទាំងឡាយឲ្យទៅជាផ្លូវច្បាប់ ស្តីពីការងារហាឡាលកម្ពុជា និងតាមដានការវិវឌ្ឍការងារហាឡាលកម្ពុជា
- រៀបចំឲ្យមានលក្ខណៈជាប្រព័ន្ធក្នុងការគ្រប់គ្រងផលិតផលហាឡាលកម្ពុជា ជាពិសេសលើការងារត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងជំរុញការនាំចេញ ព្រមទាំងការពារស្លាកសញ្ញាហាឡាលកម្ពុជា
- ផ្តល់ការឯកភាពលើវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា

- ធ្វើជាអ្នកសម្របសម្រួលក្នុងការកសាងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន
- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលរាល់បញ្ហា ដែលទាក់ទងនឹងការអភិវឌ្ឍផលិតផលហាឡាលកម្ពុជា
- ស្រាវជ្រាវ និងអភិវឌ្ឍលើខ្សែចង្វាក់ផលិតកម្មហាឡាលទាំងមូល
- ទាក់ទាញជំនួយបរទេសដើម្បីគាំទ្រលើផលិតផលហាឡាលកម្ពុជា
- ធ្វើជាមជ្ឈមណ្ឌលផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ដល់អ្នកវិនិយោគ ដែលមានបំណងអភិវឌ្ឍផលិតផលហាឡាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងតាមដាននូវរាល់គម្រោង ដែលពាក់ព័ន្ធនឹងផលិតផលហាឡាលកម្ពុជា
- ចូលរួមក្នុងកិច្ចប្រជុំកម្រិតជាតិ និងអន្តរជាតិ ក៏ដូចជាសន្និសីទនានា ស្តីពី ការអភិវឌ្ឍផលិតផលហាឡាលទូទាំងពិភពលោក
- ធ្វើរបាយការណ៍ និងផ្តល់យោបល់ជាប្រចាំ អំពីបច្ចុប្បន្នភាព និងវឌ្ឍនភាពផលិតផលហាឡាលកម្ពុជា ក៏ដូចជាអំពីព័ត៌មានទីផ្សារនៅក្រៅប្រទេសជូនរាជរដ្ឋាភិបាល
- ធ្វើជាអ្នកសម្របសម្រួលនូវរាល់កិច្ចការទាំងឡាយពាក់ព័ន្ធនឹងការងារហាឡាលកម្ពុជា
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៥.-**

**គ.ត.ផ.ហ.ក.** ត្រូវធ្វើការប្រជុំយ៉ាងតិច ០២(ពីរ)ដង ក្នុង០១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ត.ផ.ហ.ក.** អាចប្រជុំជាវិសាមញ្ញបាន។

សមាជិក **គ.ត.ផ.ហ.ក.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន **គ.ត.ផ.ហ.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេស ដែលពាក់ព័ន្ធអង្គការជាតិ អន្តរជាតិ និងផ្នែកឯកជន ចូលរួមផ្តល់យោបល់បាន។

**គ.ត.ផ.ហ.ក.** អាចមានទីប្រឹក្សាបច្ចេកទេស និងអ្នកជំនាញការជាតិ អន្តរជាតិ មួយចំនួនតាមការចាំបាច់។

**គ.ត.ផ.ហ.ក.** មានសិទ្ធិប្រើត្រារបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា ៦.-**

**គ.ត.ផ.ហ.ក.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលជានាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ត.ផ.ហ.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី ៤
## ក្រុមឯកទេសផលិតផលហាឡាល

**មាត្រា ៧.-**

ត្រូវបានបង្កើតក្រុមឯកទេសផលិតផលហាឡាលដែលស្ថិតនៅក្រោមលេខាធិការដ្ឋាន **គ.ត.ផ.ហា.ក.** ហើយដែលមានភារកិច្ចផ្តល់យោបល់ទាក់ទងនឹងផលិតផលហាឡាលជូន **គ.ត.ផ.ហា.ក.** ពិនិត្យបច្ចេកទេសស្តង់ដារ និងតាមដានការផ្តល់សេវាកម្ម ការផលិត ឬការវេចខ្ចប់ផលិតផលហាឡាលកម្ពុជា និង ចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលជាប្រធាន **គ.ត.ផ.ហា.ក.**។

**មាត្រា ៨.-**

ក្រុមឯកទេសផលិតផលហាឡាល ត្រូវដឹកនាំដោយចាងហ្វាង នៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា។ សមាសភាពជាក់ស្តែងរបស់ក្រុមឯកទេសផលិតផលហាឡាលនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.**។

**មាត្រា ៩.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមឯកទេសផលិតផលហាឡាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.**។

## ជំពូកទី ៥
## ការចេញវិញ្ញាបនបត្របញ្ជាក់
## បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា និងការត្រួតពិនិត្យ

**មាត្រា ១០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងផ្តល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផល ដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា នៅក្រសួងពាណិជ្ជកម្ម ជាមុន។

ការផ្តល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផលដោយដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" ក្នុងគោលបំណងចែកចាយ ទោះបីក្នុងគោលដៅធ្វើពាណិជ្ជកម្ម ឬមិនធ្វើពាណិជ្ជកម្ម ដោយពុំមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវហាមឃាត់។

**មាត្រា ១១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានផ្តល់សេវាកម្ម ផលិត វេចខ្ចប់ ផលិតផលហាឡាល តាមការបញ្ជាក់ពីស្ថាប័នគ្រប់គ្រងហាឡាលនៃប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ហើយដែលមានបំណងផ្តល់សេវាកម្ម ឬផលិត ឬវេចខ្ចប់ផលិតផលហាឡាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា

នៅក្រសួងពាណិជ្ជកម្ម ជាមុន។

ត្រូវបានហាមឃាត់រាល់ការផ្តល់សេវាកម្ម ការផលិត ការវេចខ្ចប់ផលិតផល ដោយដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ទោះបីជាមានការបញ្ជាក់ពីស្ថាប័នគ្រប់គ្រងហាឡាល នៃប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជា ក៏ដោយ។

**មាត្រា ១២.-**

បន្ទាប់ពីបានទទួលពាក្យស្នើសុំ **គ.ត.ផ.ហា.ក.** ត្រូវសហការជាមួយក្រុមឯកទេសផលិតផលហាឡាល ចុះដល់ទីតាំងផ្តល់សេវាកម្ម ផលិត វេចខ្ចប់ និងទីតាំងពាក់ព័ន្ធដទៃទៀត ដើម្បីត្រួតពិនិត្យទៅលើវត្ថុធាតុដើម ឬទំនិញដែលត្រូវវេចខ្ចប់ ដំណើរការនៃការផ្តល់សេវាកម្ម ផលិត វេចខ្ចប់ និងរបៀបរក្សាទុកផលិតផល។

បែបបទនៃការដាក់ពាក្យស្នើសុំវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.**។

**មាត្រា ១៣.-**

ក្នុងករណីពិនិត្យឃើញថា ការផ្តល់សេវាកម្ម ការផលិត ការវេចខ្ចប់នោះ បានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌវាយតម្លៃគុណភាពផលិតផលហាឡាលរួចហើយ **គ.ត.ផ.ហា.ក.** និងក្រុមឯកទេសផលិតផលហាឡាល ត្រូវចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ឲ្យទៅអ្នកដាក់ពាក្យស្នើសុំក្នុងរយៈពេលមិនលើសពី ០៣(បី) ខែឡើយ។ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវចេញដោយប្រធានក្រុមឯកទេសផលិតផលហាឡាល និងត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.**។

**មាត្រា ១៤.-**

លក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលជាប្រធាន **គ.ត.ផ.ហា.ក.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមឯកទេសផលិតផលហាឡាល។

ស្លាកសញ្ញា ទម្រង់ និងរយៈពេលនៃសុពលភាព របស់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមឯកទេសផលិតផលហាឡាល។

តម្លៃសេវា បែបបទសម្រាប់ដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា កម្រៃសេវាផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា និងតម្លៃសេវារដ្ឋបាល ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៥.-**

**គ.ត.ផ.ហា.ក.** មានសិទ្ធិចាត់មន្ត្រីក្រោមឱវាទ ក្រសួងពាណិជ្ជកម្ម និងអ្នកឯកទេសឲ្យចុះទៅទីតាំងផ្តល់សេវាកម្ម ផលិត វេចខ្ចប់ និងទីតាំងពាក់ព័ន្ធដទៃទៀត ដើម្បីត្រួតពិនិត្យលើបច្ចេកទេសស្តង់ដារផលិតផលហាឡាល។ ក្នុងករណីដែលរកឃើញថា អ្នកផ្តល់សេវាកម្ម អ្នកផលិត អ្នកវេចខ្ចប់ មិនបានអនុវត្តតាមលក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាលទេនោះ **គ.ត.ផ.ហា.ក.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមឯកទេសផលិតផលហាឡាល សម្រេចៈ

- ឲ្យធ្វើការកែតម្រូវ
- ដកហូតស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ពីផលិតផល
- ផ្អាកការប្រើប្រាស់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជាមួយរយៈ រហូតដល់មានការកែតម្រូវ
- ដកហូតវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា និងស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ពីផលិតផលជាស្ថាពរ។

ការត្រួតពិនិត្យលើបច្ចេកទេសស្តង់ដារផលិតផលហាឡាលពីសំណាក់ **គ.ត.ផ.ហា.ក.** មិនមែនជាឧបសគ្គដល់ការត្រួតពិនិត្យរបស់សមត្ថកិច្ចផ្សេងទៀត ដែលអនុវត្តភារកិច្ចស្របតាមលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតឡើយ។ ម្ចាស់ផលិតផល នៅតែមានកាតព្វកិច្ចអនុវត្តតាមបទដ្ឋានបច្ចេកទេសស្តង់ដារ អនាម័យ និងបរិស្ថានជាដើម ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា ១៦.-**

**គ.ត.ផ.ហា.ក.** សហការជាមួយអគ្គនាយកកាំកុងត្រូល ដើម្បីចាត់មន្ត្រី ចុះត្រួតពិនិត្យការប្រើប្រាស់ស្លាកសញ្ញា វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា លើផលិតផលនៅកន្លែងស្តុក ឬដែលចរាចរលើទីផ្សារ ឬទីតាំងផ្តល់សេវាកម្ម។

អគ្គនាយកកាំកុងត្រូល ត្រូវចាត់តាំងមន្ត្រី ចុះត្រួតពិនិត្យការប្រើប្រាស់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា លើផលិតផលនៅកន្លែងស្តុក ឬដែលចរាចរលើទីផ្សារ ឬទីតាំងផ្តល់សេវាកម្ម និង ផលិតផលហាឡាលនាំចូល។

## ជំពូកទី ៦
## ប្រភពធនធានរបស់ គ.ត.ផ.ហា.ក.

**មាត្រា ១៧.-**

**គ.ត.ផ.ហា.ក.** មានប្រភពថវិកាជាតិដែលជាឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម។ **គ.ត.ផ.ហា.ក.** ត្រូវបើកគណនីមួយនៅរតនាគារជាតិ។

**គ.ត.ផ.ហា.ក.** មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីជាធរមាន នូវមូលនិធិជំនួយដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**គ.ត.ផ.ហា.ក.** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីប្រភពហិរញ្ញប្បទាន

សហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត ដែលបម្រើដល់ការអនុវត្តការងាររបស់ខ្លួន។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១៨.-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរ ឬការដកហូតស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ពីផលិតផល
- ការព្យួរ ឬការដកហូតវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា
- ការពិន័យអន្តរការណ៍។

ទណ្ឌកម្មខាងលើនេះ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.គ.ផ.ហា.ក**។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម មានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី លើកលែងតែទណ្ឌកម្មពិន័យអន្តរការណ៍។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រមូលប្រាក់ចំណូល ដែលបានមកពីការពិន័យ ចំពោះអំពើល្មើសដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ១៩.-**

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវបង្គាប់ឲ្យមន្ត្រីកាំកុងត្រូលមានសមត្ថកិច្ច កសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណជនល្មើស រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវបង្គាប់ឲ្យមន្ត្រីកាំកុងត្រូលមានសមត្ថកិច្ច ស្នើសុំទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច រឹបអូសវត្ថុតាងនៃបទល្មើស។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្តឹង ចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទៅតុលាការរដ្ឋប្បវេណីមានសមត្ថកិច្ច។

**មាត្រា ២០.-**

អំពើក្លែងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ឬក្លែងស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា ២១.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤,០០០,០០០ (បួនលាន) រៀល ចំពោះអំពើផ្តល់សេវាកម្ម ឬផលិត ឬវេចខ្ចប់ផលិតផលដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ទោះបីជាមាន ឬគ្មានការបញ្ជាក់ពីស្ថាប័នគ្រប់គ្រងហាឡាលនៃប្រទេសណាមួយក្តី។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២២.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤,០០០,០០០ (បួនលាន) រៀល ចំពោះអំពើផលិត ឬវេចខ្ចប់ផលិតផល ឬសេវាកម្មដោយបន្តដាក់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា លើផលិតផល បន្ទាប់ពីស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវបានព្យួរ ឬដកហូត។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៣.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤,០០០,០០០ (បួនលាន) រៀល ចំពោះអំពើផលិត ឬវេចខ្ចប់ផលិតផល ឬសេវាកម្ម ដោយបន្តដាក់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជាលើផលិតផល បន្ទាប់ពីវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជាអស់សុពលភាព ឬត្រូវបានព្យួរ ឬដកហូត។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល ០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៤.-**

នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២១ ដល់មាត្រា ២៣ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០,០០០,០០០ (ដប់លាន) រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៥.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២,០០០,០០០ (ពីរលាន) រៀល ចំពោះអំពើផលិត វេចខ្ចប់

ផលិតផល ឬសេវាកម្មផលិតផលហាឡាលកម្ពុជា ដោយរំលោភលើលក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៦**.-

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៥ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៥,០០០,០០០ (ប្រាំលាន) រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៧**.-

ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលចំពោះមន្ត្រី និងបុគ្គលណាដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យបច្ចេកទេសស្តង់ដារផលិតផលហាឡាល បានរកឃើញថា ការផ្តល់សេវាកម្ម ឬផលិត ឬវេចខ្ចប់ផលិតផលហាឡាល ដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" ដោយពុំមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ឬវិញ្ញាបនបត្រនេះត្រូវបានអស់សុពលភាព ឬត្រូវបានដកហូត ឬដោយមិនបានអនុវត្តតាមលក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារហាឡាលកម្ពុជា ហើយមិនបានរាយការណ៍មក **គ.ត.ផ.ហា.ក**. ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលចំពោះមន្ត្រី និងបុគ្គលណាដែលចុះត្រួតពិនិត្យបច្ចេកទេសស្តង់ដារផលិតផលហាឡាលដោយពុំមានលិខិតបញ្ជាបេសកកម្មពី **គ.ត.ផ.ហា.ក**. ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ២៨**.-

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានផ្តល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា នៅក្រសួងពាណិជ្ជកម្ម ក្នុងអំឡុងពេល ០៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃចេញអនុក្រឹត្យនេះ។ បើផុតអំឡុងពេលនេះ ហើយរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ នៅតែមិនព្រមមកបំពេញបែបបទដាក់ពាក្យស្នើសុំទៀត នោះចាត់ទុកថា ផលិតផលទាំងនោះជាផលិតផលខុសច្បាប់ ហើយប្រឈមមុខនឹងការចាត់វិធានការតាមអនុក្រឹត្យនេះ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានផ្តល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ " حلال " តាមការបញ្ជាក់ ពីស្ថាប័នគ្រប់គ្រងហាឡាលនៃប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវអនុវត្តតាមវាក្យខណ្ឌទី១ ខាងលើនេះផងដែរ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ២៩**.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣០**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ និងចាងហ្វាងនៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ. ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣០.-
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.**.បំពាក់**មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឃ្លោក យ៉ែម** ប្រធានអង្គការសម្រេចសុបិនកុមារកម្ពុជា ដែលបានខិតខំស្វែងរកជំនួយជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ និងបង្គន់អនាម័យ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់អនុវិទ្យាល័យបួ ស្ថិតនៅភូមិបួ ឃុំបួ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៦៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ

## សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនតំណាងអង្គការកុមារមេត្តាកម្ពុជា ចំនួន៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងអគារសិក្សា ០១ខ្នង អគារស្នាក់នៅ ០៤ខ្នង អគារការិយាល័យ ០១ខ្នង និងសមិទ្ធផលនានាមួយចំនួនទៀត នៅភូមិកំណាប់ សង្កាត់បន្ទាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-លោក អ៊ីច ម៉ូត | អគ្គនាយកនៃអង្គការកុមារមេត្តា ប្រចាំក្រុងប៉ារីស |
| ២-លោក ទ្រាំ សយ | ទីប្រឹក្សានាយកជាតិអង្គការកុមារមេត្តា ប្រចាំកម្ពុជា |
| ៣-អ្នកស្រី មួរ សុជា | បុគ្គលិកទទួលបន្ទុកផ្នែកសង្គម |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧០ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

## សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីរាជការ ចំនួន ៦ រូប ជាសមាជិកនៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ដូចមានរាយនាមខាងក្រោម ៖

១- លោក **ហេន ឈុនឡាយ**

២- លោក **សុខ ច័ន្ទវាសនា**

៣- លោក **ប៊ុត សំអួន**

៤- លោក **ឡៅ ហឿន**

៥- លោក **រស់ ផើក**

៦- លោក **ជាវ ប៊ុនឡា**

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៣០ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១៖** ត្រូវបានតែងតាំងលោក **ឈាង ធីរ៉ា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **អគ្គទីប្រឹក្សា** ប្រចាំស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋបារាំង។

**មាត្រា ២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៣១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនទីប្រឹក្សាបច្ចេកទេស នៃក្រុមហ៊ុនសាងសង់ចិន ចំនួន ៣រូប ដែលមានស្នាដៃល្អក្នុងការជួយសាងសង់ផ្លូវជាតិលេខ ៤៤ ចាប់ពីច្បារមន ទីរួមខេត្តកំពង់ស្ពឺ ដល់ឧត្តុង្គ រហូតដល់រួចរាល់ជាស្ថាពរ ដូចមានរាយនាមខាងក្រោម ៖

១- Mr. **Chen Ning Deputy General Manager of CRBC**

២- Mr. **Wang Pengtao Project Manager of NR44**

៣- Mr. **Zhou Honggang Chief Engineer of NR44**

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរយោធិនពិការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១:** ផ្ទេរយោធិនពិការ នាយទាហាន នៃកងយោធពលខេមរភូមិន្ទទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | ឃុត ឆេ | អត្តលេខ ០០២០០២ | កងឯកភាព ទីចាត់ការឃោសនាព័ត៌មាន អគ្គបញ្ជាការដ្ឋាន |
| ២-ឧត្តមសេនីយ៍ទោ | ទ័រ យឿន | អត្តលេខ ០០២៩០៣ | កងឯកភាព កងពលធំអន្តរាគមន៍លេខ៣ |
| ៣-ឧត្តមសេនីយ៍ត្រី | អៀង សុផាន់ | អត្តលេខ ០០១០១៥ | កងឯកភាព យោធភូមិភាគទី៥ |
| ៤-ឧត្តមសេនីយ៍ត្រី | គង់ លីម | អត្តលេខ ០០១១៤១ | កងឯកភាព យោធភូមិភាគទី៥ |
| ៥-ឧត្តមសេនីយ៍ត្រី | ខឡូ ទិយុទ្ធ | អត្តលេខ ០០១២២៩ | កងឯកភាព កងពលតូចអន្តរាគមន៍លេខ១១ |
| ៦-វរសេនីយ៍ឯក | ខៀវ ឃី | អត្តលេខ ០០៣៩២៧ | កងឯកភាព កងពលតូចថ្មើរជើងលេខ៥៣ |
| ១៨១ | នាយចំណង់ | ឯម ស៊ីណាត | អត្តលេខ ០៦៨៥០២ ប្រធានក្រុម២ខ២គ៣ វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |
| ១៨២ | នាយចំណង់ | ហ៊ិន សាមេត | អត្តលេខ ០៧៨៩៩២ បញ្ជាការរងខ១ គ២វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |
| ១៨៣ | នាយចំណង់ | ផុន ច័ន្ទឥន្ទ្រា | អត្តលេខ ០៨៨៥៨១ ប្រធានក្រុម២ខ២គ១វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |

| | | | |
|---|---|---|---|
| ១៨៤ | នាយចំណង់ | មិន ប្រុស | អត្តលេខ ១០៧៥៤៩ បុគ្គលិកដឹកជញ្ជូន បញ្ជាការដ្ឋានបញ្ជូនសារ |
| ១៨៥ | នាយចំណង់ | កែវ រតនា | អត្តលេខ ០៧៩៧៤៦ ជំនួយការសុខាភិបាល វរសេនាតូចលេខ៦៦ បញ្ជាការដ្ឋានរថក្រោះ |
| ១៨៦ | នាយចំណង់ | សំ អាន | អត្តលេខ ១០០៧៦៥ នាយរងយានដ្ឋានជួសជុល បញ្ជាការដ្ឋានរថក្រោះ |
| ១៨៧ | នាយចំណង់ | ទូច ពៅ | អត្តលេខ ១៣១១០៤ បញ្ជាការរង កងអនុសេនាតូចទី២ កងអនុសេនាធំវិស្វកម្ម បញ្ជាការដ្ឋានរថក្រោះ |
| ១៨៨ | នាយចំណង់ | សយ សំណាង | អត្តលេខ ០៧៣៤៣៦ នាយក្រុម២ កងអនុសេនាតូចទី១ កងអនុសេនាធំវិស្វកម្ម បញ្ជាការដ្ឋានរថក្រោះ |
| ១៨៩ | នាយចំណង់ | ហឿន ចំនិត | អត្តលេខ ២៣៥៦៨៥ នាយទាហាន ការិយាល័យទី១ កងទ័ពជើងគោក |
| ១៩០ | នាយចំណង់ | លុយ មៀកគ្រីឌី | អត្តលេខ ១៨៧២៥២ នាយទាហាន ការិយាល័យទី២ កងទ័ពជើងគោក |
| ១៩១ | នាយចំណង់ | មាស ពៅ | អត្តលេខ ១៣៥៧៦៨ មេបញ្ជាការ អនុសេនាតូចទី៣ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៩២ | នាយចំណង់ | ស៊ូ ខុឡា | អត្តលេខ ០៧២២១២ ជំនួយការផ្នែកហ្វឹកហ្វឺន ការិយាល័យការពារព្រំដែនគោក |
| ១៩៣ | នាយចំណង់ | ឡេង ចេង | អត្តលេខ ២៣២៤៨១ ជំនួយការផ្នែកបញ្ជូនសារ ការិយាល័យការពារព្រំដែនគោក |
| ១៩៤ | នាយចំណង់ | គា សុគ័ន្ធ | អត្តលេខ ១៩០៧៣៩ ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យការពារព្រំដែនគោក |
| ១៩៥ | ព្រិន្ទបាលឯក | អ៊ាច ម៉េងស៊ាន់ | អត្តលេខ ០៨២០៧៨ នាយក្រុម៧ កងអនុសេនាតូចទី៣ កងអនុសេនាធំទី១ វរសេនាតូចលេខ៦៦ |
| ១៩៦ | ព្រិន្ទបាលឯក | ឈឿម សុភាព | អត្តលេខ ២១៥៨៦២ ជំនួយការធានា វរសេនាតូចលេខ៦៦ បញ្ជាការដ្ឋានរថក្រោះ |
| ១៩៧ | ព្រិន្ទបាលឯក | យ៉ន អ៊ាន់នឿន | អត្តលេខ ០៥៤៦៤៥ ជំនួយការបច្ចេកទេស វរសេនាតូចលេខ៦៦ បញ្ជាការដ្ឋានរថក្រោះ |
| ១៩៨ | ព្រិន្ទបាលឯក | ហម ប៊ុនឡាយ | អត្តលេខ ០៦២១៩៦ បញ្ជាការកងអនុសេនាតូចទី៤ កងអនុសេនាធំទី២ វរសេនាតូចលេខ៦៦ |
| ១៩៩ | ព្រិន្ទបាលឯក | ហឿក តារៈ | អត្តលេខ ០៧៧០៦០ បញ្ជាការរងកងអនុសេនាតូចទី៧ កងអនុសេនាធំទី៣ វរសេនាតូចលេខ៦៦ |
| ២០០ | ព្រិន្ទបាលឯក | ចលិ ផល | អត្តលេខ ១៣៥៧៩៤ មេបញ្ជាការរង អនុសេនាតូចទី២ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ២០១ | ព្រិន្ទបាលឯក | ស្រស់ សុជា | អត្តលេខ ០៩៣៥០៨ ជំនួយការភស្តុភារ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ២០២ | ព្រិន្ទបាលឯក | គិង ចាន់ឡុង | អត្តលេខ ០៦២៣៥០ បុគ្គលិក ហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ៥៣ |
| ២០៣ | ព្រិន្ទបាលឯក | ទឿន រស្មី | អត្តលេខ ១៣១៤៧៦ បុគ្គលិក ចលនូប្បត្ថម្ភ វរសេនាតូចលេខ៥៣៤ កងពលតូចថ្មើរជើងលេខ៥៣ |
| ២០៤ | ព្រិន្ទបាលឯក | ជា រម្យ | អត្តលេខ ៧៣១១២ មន្ត្រីផ្នែកយុតិធម៍ អធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ២០៥ | ព្រិន្ទបាលឯក | អ៊ុត តយ | អត្តលេខ ០៧៥១០១ បុគ្គលិកជួសជុល ការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ២០៦ | ព្រិន្ទបាលឯក | ឈាន កែវសុវណ្ណារី | អត្តលេខ ០៨៨៤៨៧ បញ្ជាការរងខ២គ២វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |
| ២០៧ | ព្រិន្ទបាលឯក | សុខ ឆាយ | អត្តលេខ ១៨៨៩៩៦ ប្រធានក្រុម៣ខ២គ៣វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |
| ២០៨ | ព្រិន្ទបាលឯក | គ្រឿន សុវត្ថិ | អត្តលេខ ២៣៣២៦៥ បញ្ជាការរងខ១គ៣វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |
| ២០៩ | ព្រិន្ទបាលឯក | ម៉ែន ទុទ្ធី | អត្តលេខ ២៣៧២៥៨ បញ្ជាការរងខ១គ១វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |
| ២១០ | ព្រិន្ទបាលឯក | ជា គីមសុទ្ធ | អត្តលេខ ២៣៧៩៦៦ បញ្ជាការរងខ២គ៣វរ៥៤ បញ្ជាការដ្ឋានបញ្ជូនសារ |
| ២១១ | ពលបាលឯក | តេន សុគៀត | អត្តលេខ ២២៧៥១៣ អ្នកបាញ់កាំភ្លើងលើរថក្រោះ វរសេនាតូចលេខ៦៦ |
| ២១២ | នាយឯក | ឈុន ម៉េង | អត្តលេខ ២០៣៦៨០ នាយទាហាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក |
| ២១៣ | ពលទោ | ប៊ូ វណ្ណឌី | អត្តលេខ ១៩៨៣៦០ ជំនួយការ បញ្ជាការដ្ឋានបញ្ជូនសារ |
| ២១៤ | លោក | ភាណារុល វិទ្ធរ្យ | អនុប្រធាន ការិយាល័យ នៃអគ្គនាយកដ្ឋានរតនាគារជាតិ |
| ២១៥ | លោក | ប៊ុន សុខមេនា | អនុប្រធាន ការិយាល័យ នៃអគ្គនាយកដ្ឋានរតនាគារជាតិ |

| | | | |
|---|---|---|---|
| ២១៦ | លោកស្រី | **ហួន រ៉ាដែត** | មន្ត្រី នៃអគ្គនាយកដ្ឋានរតនាគារជាតិ |
| ២១៧ | លោក | **តាត សោភ័ណ្ឌ** | មន្ត្រី នៃអគ្គនាយកដ្ឋានរតនាគារជាតិ |
| ២១៨ | លោក | **អ៊ុក វណ្ណារ៉ា** | មន្ត្រី នៃអគ្គនាយកដ្ឋានរតនាគារជាតិ |
| ២១៩ | លោក | **សំ ណាង** | អនុប្រធានកងបច្ចេកទេស កងវិស្វកម្មតេជោ ហ៊ុន សែន សៀមរាប |
| ២២០ | លោក | **យិច ប្រុញ** | ប្រធានកងវាស់វែង កងវិស្វកម្មតេជោ ហ៊ុន សែន សៀមរាប |
| ២២១ | លោក | **ហ៊ិន ហុង** | អនុប្រធានកងវាស់វែង កងវិស្វកម្មតេជោ ហ៊ុន សែន សៀមរាប |
| ២២២ | លោក | **អ៊ឹម វិសាល** | មន្ត្រី នៃក្រសួងពាណិជ្ជកម្ម |

**ខ-មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១ | ឧត្តមសេនីយ៍ត្រី | **សុខ ម៉ាយ៉េត** | អត្តលេខ ០៦៨៣៦៨ នាយទាហាន ខុទ្ទកាល័យ កងទ័ពជើងគោក |
| ២ | វរសេនីយ៍ឯក | **កែវ សុខពិសាល** | អត្តលេខ ០៥០២៦៦ ជំនួយការ ការិយាល័យទី៥ កងទ័ពជើងគោក |
| ៣ | វរសេនីយ៍ទោ | **កែវ សុខពិសដ្ឋ** | អត្តលេខ ២២៧០៦៣ ជំនួយការ ការិយាល័យទី៥ កងទ័ពជើងគោក |
| ៤ | វរសេនីយ៍ត្រី | **ពេជ្រ មុនី** | អត្តលេខ ០០៩៧៤២ ជំនួយការផ្នែកផែនការបូកសរុប ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ៥ | អនុសេនីយ៍ឯក | **សុង តារាវុធ** | អត្តលេខ ១៤៦៦១៦ ជំនួយការផ្នែកគ្រប់គ្រងបើកចែក ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ៦ | អនុសេនីយ៍ឯក | **ថាន់ សុទ្ធិសិទ្ធ** | អត្តលេខ ០៨៨៦២២ ជំនួយការផ្នែកគណនេយ្យ ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ៧ | អនុសេនីយ៍ឯក | **ខ៊ុំវ ឌីណា** | អត្តលេខ ០៧២១០៦ ជំនួយការផ្នែកគណនេយ្យ ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ៨ | អនុសេនីយ៍ឯក | **សុខ សោភ័ណ** | អត្តលេខ ១៤០៥៧៨ ជំនួយការផ្នែកបុគ្គលិក បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៩ | អនុសេនីយ៍ទោ | **ភួង ម៉ារី** | អត្តលេខ ២០៨៤៧៦ ជំនួយការផ្នែកបច្ចេកទេស បញ្ជាការដ្ឋានកាំភ្លើងធំ |
| ១០ | អនុសេនីយ៍ទោ | **ប៊ិន សារ៉េន** | អត្តលេខ ០៦៧៣៨៧ ជំនួយការបណ្តុះបណ្តាល ការិយាល័យទី១ កងពលតូចថ្មើរជើងលេខ៥៣ |
| ១១ | អនុសេនីយ៍ទោ | **ខៀវ វិសាល** | អត្តលេខ ៥៦៧១០ នាយរងផ្នែកព្រហ្មទណ្ឌ អធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ១២ | អនុសេនីយ៍ទោ | **អ៊ិន ឆន** | អត្តលេខ ៤៣៥៩២ នាយរងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ អធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ១៣ | អនុសេនីយ៍ទោ | **ហេង លីដា** | អត្តលេខ ១៣៦៦១៩ នាយទាហាន ខុទ្ទកាល័យ កងទ័ពជើងគោក |
| ១៤ | អនុសេនីយ៍ទោ | **ម៉ក់ សុភក្តិ** | អត្តលេខ ០៦៦៩៥១ នាយទាហាន ការិយាល័យទី២ កងទ័ពជើងគោក |
| ១៥ | អនុសេនីយ៍ទោ | **សោម សុវណ្ណា** | អត្តលេខ ០៦៨៧៥៥ នាយទាហាន ការិយាល័យទី៤ កងទ័ពជើងគោក |
| ១៦ | អនុសេនីយ៍ទោ | **ស សុវណ្ណា** | អត្តលេខ ០៦៨៨០០ នាយទាហាន ការិយាល័យទី៤ កងទ័ពជើងគោក |
| ១៧ | អនុសេនីយ៍ទោ | **តែ អ៊ុច** | អត្តលេខ ០៣៣៥៥៧ ជំនួយការផ្នែកគណនេយ្យ ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ១៨ | អនុសេនីយ៍ទោ | **រ៉ាយ សារី** | អត្តលេខ ១៤៣០០៣ ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ១៩ | អនុសេនីយ៍ទោ | **ជ័យ រិទ្ធី** | អត្តលេខ ០៥២២០៥ ជំនួយការផ្នែកផែនការបូកសរុប ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ២០ | អនុសេនីយ៍ត្រី | **ហ៊ែល សម្ផស្ស** | អត្តលេខ ១៥៧៣១១ នាយទាហាន ការិយាល័យទី៤ កងទ័ពជើងគោក |
| ២១ | អនុសេនីយ៍ត្រី | **ហូ សុភាព** | អត្តលេខ ១៦៣៤៩០ នាយទាហាន ការិយាល័យទី៤ កងទ័ពជើងគោក |
| ២២ | អនុសេនីយ៍ត្រី | **ដួង ចិន្តា** | អត្តលេខ ១៥០១០១ ជំនួយការផ្នែកលេខាធិការដ្ឋាន បញ្ជាការដ្ឋានរថក្រោះ |
| ២៣ | អនុសេនីយ៍ត្រី | **យូ សុខនៅ** | អត្តលេខ ០៧៣៩៥៣ ជំនួយការផ្នែកសុខាភិបាល បញ្ជាការដ្ឋានកាំភ្លើងធំ |
| ២៤ | អនុសេនីយ៍ត្រី | **យិន ឆឿន** | អត្តលេខ ០៧៣៧៣៧ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ២៥ | អនុសេនីយ៍ត្រី | **យុន រតនារ៉ាវឌី** | អត្តលេខ ១៦២៨០០ ជំនួយការផ្នែកសុខាភិបាល បញ្ជាការដ្ឋានកាំភ្លើងធំ |
| ២៦ | អនុសេនីយ៍ត្រី | **រស់ ណារីន** | អត្តលេខ ០៧៣៦១៣ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |

| | | | |
|---|---|---|---|
| ២៧ | អនុសេនីយ៍ត្រី | **នួន កុសល** | អត្តលេខ ២០៧៦៤២ ជំនួយការផ្នែកលេខាធិការដ្ឋាន បញ្ជាការដ្ឋានរថក្រោះ |
| ២៨ | នាយចំណង់ | **ចាន់ សុខារី** | អត្តលេខ ១៥១៩០៦ ជំនួយការផ្នែកលេខាធិការដ្ឋាន បញ្ជាការដ្ឋានរថក្រោះ |
| ២៩ | នាយចំណង់ | **ពៅ ពិសី** | អត្តលេខ ១៣៩២៩៩ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៣០ | នាយចំណង់ | **ឆែម គឿង** | អត្តលេខ ០៨២២២២ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៣១ | នាយចំណង់ | **សូ សំណាង** | អត្តលេខ ០៧៥៩៦០ ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក |
| ៣២ | ព្រិន្ទបាលឯក | **នួច លីដា** | អត្តលេខ ២២៨៧៩៣ ជំនួយការប្រេង ការិយាល័យបច្ចេកទេស កងពលតូចថ្មើរជើងលេខ៥៣ |
| ៣៣ | ព្រិន្ទបាលឯក | **សាន់ ផល** | អត្តលេខ ៤៤២៥៩ នាយរងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ អធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣៤ | ព្រិន្ទបាលឯក | **ប៊ិច ចំរើន** | អត្តលេខ ៤៤២៦៧ នាយរងផ្នែកស្ថិតិ អធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣៥ | ព្រិន្ទបាលឯក | **អ៊ិន វឌ្ឍនះ** | អត្តលេខ ៦៧១៥១ មន្ត្រី អធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣៦ | ព្រិន្ទបាលឯក | **ពៅ និមល** | អត្តលេខ ០៨៥១៦០ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៣៧ | ព្រិន្ទបាលឯក | **អឿន ផូ** | អត្តលេខ ១១៣២៨៤ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៣៨ | ព្រិន្ទបាលឯក | **គេច រតនា** | អត្តលេខ ០៨៨៥៣៣ នាយទាហានរង ការិយាល័យទី៤ កងទ័ពជើងគោក |
| ៣៩ | ព្រិន្ទបាលឯក | **សំ ដារ៉ា** | អត្តលេខ ២៤២៣២៥ នាយទាហានរង ការិយាល័យទី៤ កងទ័ពជើងគោក |

**គ-មេដាយសំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| ១ | អនុសេនីយ៍ទោ | **គួន វណ្ណៈ** | អត្តលេខ ០៦៧៣០១ ជំនួយការលិខិតស្នាមលេខាធិការដ្ឋាន កងពលតូចថ្មើរជើងលេខ៥៣ |
| ២ | អនុសេនីយ៍ទោ | **ម៉ាន់ វិបុល** | អត្តលេខ ០៦៧០៥៤ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៣ | អនុសេនីយ៍ត្រី | **ហ៊ាង រតនា** | អត្តលេខ ០៧៦៣៣៣ ជំនួយការការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ៤ | អនុសេនីយ៍ត្រី | **គីម ហាន** | អត្តលេខ ២៤១៦៥៩ មេបញ្ជាការរង ផ្នែកសឹករងអង្គរជ័យ តំបន់ប្រតិបត្តិការសឹករងតាកែវ |
| ៥ | នាយចំណង់ | **ផេង ធិតា** | អត្តលេខ ០៦៥៤៤២ បុគ្គលិកបញ្ជូនសារអនុសេនាធំ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៦ | នាយចំណង់ | **វ៉េត រតនា** | អត្តលេខ ០៨៩៣៦៩ ជំនួយការ បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៧ | នាយចំណង់ | **ប៉ែន សារ៉ុ** | អត្តលេខ ១៣៥៧០៥ រងអនុសេនាតូចទី៣ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ៨ | ព្រិន្ទបាលឯក | **ម៉ៅ ពិសិដ្ឋ** | អត្តលេខ ០៧៣៩០៩ បុគ្គលិក ហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ៥៣ |
| ៩ | ព្រិន្ទបាលឯក | **ឌុច ប៊ុនធី** | អត្តលេខ ០៧៦៤៧០ បុគ្គលិក ការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ១០ | ព្រិន្ទបាលឯក | **ចាន់ សុត្ថនា** | អត្តលេខ ០៩៥៧៣៣ បុគ្គលិក ការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ១១ | ព្រិន្ទបាលឯក | **គុន លីមសុវណ្ណ** | អត្តលេខ ០៧៧៤៣៩ បុគ្គលិក ការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ១២ | ព្រិន្ទបាលឯក | **ប៉ែន សំបូរ** | អត្តលេខ ១៣៥៦៨០ នាយក្រុម១ អនុសេនាតូចទី១ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៣ | ព្រិន្ទបាលឯក | **ស៊ីន មឿន** | អត្តលេខ ២០៧២៩៦ រងអនុសេនាតូចទី១ អនុសេនាធំទី២ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៤ | ព្រិន្ទបាលឯក | **អ៊ុន អត** | អត្តលេខ ២០៧២៧៩ រងអនុសេនាតូចទី២ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៥ | ព្រិន្ទបាលឯក | **អ៊ុន សុផល** | អត្តលេខ ១៥៧០១១ នាយក្រុម១ អនុសេនាតូចទី១ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៦ | ព្រិន្ទបាលឯក | **វ៉ាន់ ផេង** | អត្តលេខ ២០៧១៤២ បុគ្គលិកបំរើការ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៧ | ព្រិន្ទបាលឯក | **ទុយ វណ្ណារ៉ា** | អត្តលេខ ១៣៥៦៩៩ រងក្រុម២ អនុសេនាតូចទី៣ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៨ | ព្រិន្ទបាលឯក | **យិន វ៉ាន់ធីម** | អត្តលេខ ២០៧២២២ ជំនួយការហ្វឹកហ្វឺន ផ្នែកសឹករងមណ្ឌលសីម៉ា |
| ១៩ | ព្រិន្ទបាលឯក | **ប៊ុច ម៉ុច** | អត្តលេខ ១៤១២៩៦ ជំនួយការហ្វឹកហ្វឺន ផ្នែកសឹករងមណ្ឌលសីម៉ា |
| ២០ | ព្រិន្ទបាលឯក | **មឿក យឿន** | អត្តលេខ ១៩៨២៨៩ នាយក្រុមអនុសេនាធំជួសជុលរថក្រោះ បញ្ជាការដ្ឋានរថក្រោះ |

| | | | |
|---|---|---|---|
| ២១ | ព្រិន្ទបាលទោ | **ឃុន សុខា** | អត្តលេខ ០៨២៨៨៧ ជំនួយការផ្នែកបច្ចេកទេស បញ្ជាការដ្ឋានរថក្រោះ |
| ២២ | ព្រិន្ទបាលទោ | **អ៊ីុច សុភាព** | អត្តលេខ ២០៧១៩១ មេក្រុម១ អនុសេនាតូចទី៣ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ២៣ | ព្រិន្ទបាលទោ | **អ៊ឹម សុខុម** | អត្តលេខ ០៦៥២៨៤ រងអនុសេនាតូចទី១ អនុសេនាធំទី២ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ២៤ | ព្រិន្ទបាលទោ | **អេះ ម៉ាត់** | អត្តលេខ ១៨៧៤០៣ រងក្រុម២ អនុសេនាតូចទី២ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ២៥ | ព្រិន្ទបាលទោ | **សួន អ៊ីន** | អត្តលេខ ០៨៣៦១៥ បុគ្គលិក ការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ២៦ | ព្រិន្ទបាលទោ | **សរ សុវណ្ណា** | អត្តលេខ ១៣១៦២៧ បុគ្គលិក ការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ២៧ | ព្រិន្ទបាលទោ | **ម៉ាច ពៅធីតា** | អត្តលេខ ០៨៣៦០៩ បុគ្គលិក ការិយាល័យបច្ចេកទេស យោធភូមិភាគទី៥ |
| ២៨ | ពលបាលឯក | **ខែ បណ្ឌិត** | អត្តលេខ ២៤០៥៧២ បុគ្គលពេទ្យ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ២៩ | ពលបាលឯក | **តាន់ អេង** | អត្តលេខ ២៤០៤៥៧ មេក្រុម១ អនុសេនាតូចទី១ អនុសេនាធំទី២ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ៣០ | ពលបាលឯក | **ស៊ី ម៉ីន** | អត្តលេខ ២៤០៤៧០ មេក្រុម២ អនុសេនាតូចទី១ អនុសេនាធំទី២ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ៣១ | ពលបាលឯក | **ណោម ដេង** | អត្តលេខ ២៤០៤៦៣ មេក្រុម៣ អនុសេនាតូចទី១ អនុសេនាធំទី២ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ៣២ | ពលបាលឯក | **សុខ ម៉ាន់** | អត្តលេខ ២៣០៤៦១ យុទ្ធជន អនុសេនាតូចទី២ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ៣៣ | ពលបាលឯក | **លី អ៊ីសា** | អត្តលេខ ២៣០៤២៨ រងក្រុម២ អនុសេនាតូចទី២ អនុសេនាធំទី១ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ៣៤ | ពលបាលឯក | **អូន ជាណាក់** | អត្តលេខ ២៤០៤៧៥ ជំនួយការប្រតិបត្តិការ ផ្នែកសឹករងមណ្ឌលសីម៉ា |
| ៣៥ | ពលបាលឯក | **ជា ចាន់ថៃ** | អត្តលេខ ២០១៤៣៧ ជំនួយការផ្នែកធានាស បញ្ជាការដ្ឋានរថក្រោះ |
| ៣៦ | ពលទោ | **យឹម សុផល** | អត្តលេខ ០៥៩៧៥៤ បុគ្គលិកបញ្ជូនសារ បញ្ជាការដ្ឋានបញ្ជូនសារ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៧៧.សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការជ្រើសរើសពលទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្ដីពី ការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** អនុញ្ញាតឲ្យក្រសួងការពារជាតិ ជ្រើសរើសពលទាហាន ចំនួន ៥០០(ប្រាំរយ)នាក់ សម្រាប់បំពេញក្របខ័ណ្ឌឲ្យ៖

-បញ្ជាការដ្ឋានអង្គរក្ស អគ្គបញ្ជាការដ្ឋាន ចំនួន ៣៥០(បីរយហាសិប)នាក់

-យោធភូមិភាគពិសេស បញ្ជាការដ្ឋានកងទ័ពជើងគោក ចំនួន ១៥០(មួយរយហាសិប)នាក់

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ : ..៧៤៥..សសរ**

**សេចក្តីសម្រេច**

**ស្តីពី**

**ការផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.-**

ត្រូវបានផ្លាស់ប្តូរឯកឧត្តម **កែវ ស៊ីវន** អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ពីសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តព្រះវិហារ មកជាសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ ។

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋបាលខេត្តព្រះវិហារ រដ្ឋបាលខេត្តតាកែវ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៦

__កន្លែងទទួល:__

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**តប.នាយករដ្ឋមន្ត្រី**
**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ..៧២..សសរ.

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងប្រធាននិងអនុប្រធានក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានតែងតាំងប្រធាន អនុប្រធាន ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តក្រចេះដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្ដម **ពេជ្រ ប៊ុនធិន** | រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២-ឯកឧត្ដម **ឌី ច័ន្ទផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

**ប្រការ២.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តក្រចេះ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>*កន្លែងទទួល:*</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៧៦១......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការចំណាត់ថ្នាក់សម្រាប់វាយតម្លៃ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៤/៨៦១ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការតែងតាំងមន្ត្រីរាជការ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៥៥៨ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការតម្លើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ និងតម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល
- ប្រកាសលេខ ៧១៥ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ទូរសារ :៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតគណៈកម្មការចំណាត់ថ្នាក់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងវាយតម្លៃការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ ២.–**

សមាសភាពគណៈកម្មការចំណាត់ថ្នាក់ក្រសួង រួមមាន÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ | អនុប្រធាន |
| ៣. លោក **វ៉ៅម សុវណ្ណា** | អគ្គលេខាធិការរង | សមាជិក |
| ៤. លោក **ម៉ុត សទ្វារ** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥. លោកស្រី **ថោង វណ្ណសុជីវី** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦. លោក **ផន ផុន** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧. លោក **ប៉ូយ វណ្ណាហឿន** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៨. លោក **សួស សេរីវឌ្ឍនា** | ប្រធានការិយាល័យបៀវត្ស | លេខាធិការ ។ |

**ប្រការ ៣.–**

គណៈកម្មការចំណាត់ថ្នាក់ក្រសួងមានភារកិច្ចដូចតទៅ÷

- ពិនិត្យព្រឹត្តិប័ត្រកំណត់ពិន្ទុវិជ្ជាជីវៈនិងស្ថានភាពសេវាកម្មរបស់មន្ត្រីរាជការម្នាក់ៗ ដែលត្រូវស្នើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិ
- រៀបចំតារាងដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការក្រសួងសម្រាប់ឆ្នាំនីមួយៗ
- កំណត់មធ្យមភាគនៃពិន្ទុចំពោះបេក្ខជនម្នាក់ៗពីពិន្ទុ ០ ដល់ ពិន្ទុ ២០ និងស្រង់ឈ្មោះបេក្ខជនតាមលំដាប់លំដោយពិន្ទុ
- កំណត់ការចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ផ្អែកតាមចំនួនកន្លែងដែលមានសល់ និងត្រូវបានអនុញ្ញាត ផ្អែកតាមវេនជ្រើសរើស និង/ឬ វេនអតីតភាព
- រៀបចំបញ្ជីឈ្មោះមន្ត្រីរាជការដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ព្រមទាំងធ្វើរបាយការណ៍ដាក់ជូនប្រធានស្ថាប័នពិនិត្យសម្រេច ។

**ប្រការ ៤.–**

នាយកដ្ឋានបុគ្គលិកមានភារកិច្ចរៀបចំសំណុំឯកសារ និងទម្រង់បែបបទពាក់ព័ន្ធនឹងសំណើដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ដាក់ជូនគណៈកម្មការចំណាត់ថ្នាក់ក្រសួង ។

**ប្រការ ៥.–**

ប្រកាសលេខ ១៤១ សហវ.ប្រក.ប ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការចំណាត់ថ្នាក់សម្រាប់វាយតម្លៃការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ  សាសនា  ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៨៧៨ សហវ.ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ទូរសារ :៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664    Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- ប្រកាសលេខ០៦៨ សហវ.ប្រក ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- យោងចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី លើលិខិតលេខ ១២៥៨ សហវ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យរដ្ឋបាលខេត្តចំនួន ០៦ អនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកាចាប់ពីឆ្នាំ ២០១៧ ដែលរួមមាន÷ ខេត្តកែប ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តប៉ៃលិន ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។

**ប្រការ ២.-**

រដ្ឋបាលខេត្តទាំង០៦ ត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធី និងអង្គភាពថវិកាក្នុងឆ្នាំ២០១៧ ស្របតាមប្រតិទិននៃការរៀបចំប្រចាំឆ្នាំ។

**ប្រការ ៣.-**

រដ្ឋបាលខេត្តទាំង០៦ មានភារកិច្ចដើម្បីអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា ឱ្យទទួលបានជោគជ័យ និងប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ តាមទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា។

**ប្រការ ៤.-**

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤
  "ដើម្បីអនុវត្ត"
- អគ្គនាយកដ្ឋានរាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ............១៧៣.......ក.ប/ប្រ.ក

ក្រសួងសុខាភិបាល

# ប្រកាសអន្តរក្រសួង
## ស្តីពី
## យន្តការទូទាត់ថ្លៃសេវាថែទាំសុខភាព

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់យន្តការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ សេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាព ដែល ប.ស.ស ត្រូវផ្តល់ជូនមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង ឬ មូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាសង្គ្រោះបន្ទាន់។

**ប្រការ ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅ ៖

- *យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព* សំដៅដល់វិធីសាស្ត្រនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាព ។
- *សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រ និងសេវាជំនួយវេជ្ជសាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា។
- *សេវាស្តារនីតិសម្បទា* គឺជាសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់ផ្នែកថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬ ធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាព ជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬ ខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

- ***វិធីសាស្ត្រទូទាត់តាមករណី*** សំដៅដល់ការទូទាត់ក្នុងអត្រាថេរមួយ ដែលគ្របដណ្តប់លើគ្រប់តម្លៃសេវាសម្រាប់មួយករណីនៃអ្នកជំងឺម្នាក់ ឬប្រភេទជំងឺជាក់លាក់ណាមួយ។
- ***វិធីសាស្ត្រទូទាត់តាមប្រភេទសេវា*** គឺជាការទូទាត់ថ្លៃសេវាដោយផ្អែកទៅលើប្រភេទសេវាផ្សេងៗគ្នា ហើយមានតម្លៃដាច់ដោយឡែកពីគ្នា។
- ***អន្តរាគមន៍*** សំដៅដល់សកម្មភាពព្យាបាល ឬជួយសង្គ្រោះជនរងគ្រោះ ឬអ្នកជំងឺដែលស្ថិតនៅក្នុងស្ថានភាពរឹករវ។
- ***មូលដ្ឋានសុខាភិបាល*** សំដៅដល់អង្គភាពព្យាបាលសាធារណៈ ឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

**ប្រការ ៣.-**

យន្តការនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានកំណត់តាមវិធីសាស្ត្រពីរយ៉ាង គឺវិធីសាស្ត្រទូទាត់ថ្លៃតាមករណី និង វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា។

វិធីសាស្ត្រទូទាត់ថ្លៃតាមករណី ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់តាមអត្រាតម្លៃថេរតាមប្រភេទករណីជំងឺ និងតាមកម្រិតមូលដ្ឋានសុខាភិបាលនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា ត្រូវបានអនុវត្តចំពោះប្រភេទសេវាសម្រាប់ករណីពិសេស ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

វិធីសាស្ត្រដែលកំណត់នៅក្នុងប្រកាសនេះ ត្រូវអនុវត្តសម្រាប់ផ្នែកថែទាំសុខភាព ដែលស្ថិតនៅក្នុងដែនអនុវត្តរបស់ ប.ស.ស និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា។

**ប្រការ ៤.-**

ប.ស.ស ត្រូវទូទាត់សងទៅមូលដ្ឋានសុខាភិបាល ឬសាមីជន តាមវិធីសាស្ត្រទូទាត់ថ្លៃដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ក្នុងករណីសង្គ្រោះបន្ទាន់។ ក្នុងករណីនេះ ជនរងគ្រោះ ឬ អ្នកជំងឺអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត ។

ប្រសិនបើ ការសង្គ្រោះបន្ទាន់ធ្វើនៅក្នុងមូលដ្ឋានសុខាភិបាល ដែលមិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស សាមីជន ឬ អ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មក ប.ស.ស។

**ប្រការ ៥.-**

ការទូទាត់ថ្លៃសេវាបញ្ជូនជនរងគ្រោះ ឬ អ្នកជំងឺ សម្រាប់ផ្នែកថែទាំសុខភាព ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ ដែលប្រើប្រាស់ប្រភេទមធ្យោបាយបញ្ជូនដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬមធ្យោបាយផ្សេងទៀតដែលមានលិខិតបញ្ជាក់ច្បាស់លាស់។

ការទូទាត់ថ្លៃសេវាបញ្ជូន ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៦.-**

ការបញ្ជូនសព ឬ បញ្ជូនអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬ ប្រភេទមធ្យោបាយជាក់ស្តែងផ្សេងទៀត។ ការទូទាត់ថ្លៃសេវាបញ្ជូននេះ ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៧.-**

ការទូទាត់ថ្លៃសេវាស្តារនីតិសម្បទា ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ។

**ប្រការ ៨.-**

របៀបទូទាត់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ចំពោះមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្តីពីកិច្ចព្រមព្រៀងប្រើប្រាស់និងផ្តល់សេវារវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយមូលដ្ឋានសុខាភិបាល ដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**ប្រការ ៩.-**

រៀងរាល់ដំណាច់ឆ្នាំ ប.ស.ស ត្រូវវិភាគវាយតម្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ដោយផ្អែកលើតម្លៃសេវាហិរញ្ញប្បទាន និងតម្លៃចំណាយផ្សេងៗ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

ការកែប្រែប្រភេទករណី ឬតម្លៃទូទាត់សេវាដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីបានទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស។

និយមន័យនៃករណីក្នុងយន្តការទូទាត់ថ្លៃសេវាដូចមាន ចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ អាចត្រូវបានកំណត់ឡើងវិញ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីបានទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស។

**ប្រការ ១០.-**

វិធីសាស្ត្រទូទាត់ដទៃទៀត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស ដោយយោង

តាមស្ថានភាពជាក់ស្តែង នៃការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងការវិភាគហិរញ្ញវត្ថុនៃផ្នែកថែទាំសុខភាព។

**ប្រការ ១១.-**

នាយកបេឡាជាតិរបបសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភាឆ្នាំ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*

## វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទករណី

ឧបសម្ព័ន្ធនេះមានគោលបំណងរៀបចំវិធីសាស្ត្រទូទាត់ថ្លៃតាមករណី សំរាប់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ផ្នែកថែទាំសុខភាព។ ទិដ្ឋភាពរួមនៃវិធីសាស្ត្រទូទាត់តាមករណីត្រូវបានចែងនៅក្នុងតារាងភ្ជាប់មកជាមួយ។

**១-ចំនួន និងកំរិតប្រភេទករណី៖** (ជួរឈរលេខ១ក្នុងតារាង) វិធីសាស្ត្រទូទាត់តាមករណីបានកំណត់យកប្រភេទករណី សរុបចំនួន ៩៩ ដែលត្រូវបានបែងចែកចេញជា ៥ កំរិតនៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រគឺ: កំរិត MPA សំរាប់មណ្ឌលសុខភាព កំរិត CPA1 សំរាប់មន្ទីរពេទ្យបង្អែកកំរិត១ កំរិត CPA2 សំរាប់មន្ទីរពេទ្យបង្អែកកំរិត២ កំរិត CPA3 សំរាប់មន្ទីរពេទ្យបង្អែកកំរិត៣ និង កំរិត NH សំរាប់មន្ទីរពេទ្យជាតិ ដូចមានចែងនៅក្នុងគោលការណ៍ណែនាំស្តីពីសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់របស់ក្រសួងសុខាភិបាល។

**២-លេខកូដ៖** (ជួរឈរលេខ២ក្នុងតារាង) រាល់ប្រភេទករណីនីមួយៗមានលេខកូដមួយ ដែលផ្គុំឡើងដោយតួអក្សរឡាតាំង៣តួនៅខាងមុខ និងលេខមួយតួនៅខាងចុង។ អក្សរឡាតាំងទាំង៣តួ ភាគច្រើនបំផុត យកចេញពីតួអក្សរឡាតាំង៣តួ ដំបូងនៃឈ្មោះករណីដែលអាចចាត់ទុកថាជាឈ្មោះសង្ខេប រីឯលេខមួយតួខាងចុងតំណាងកំរិតសេវា ពោលគឺ: លេខ0 តំណាងកំរិតMPA, លេខ1 តំណាងកំរិតCPA1, លេខ2 តំណាងកំរិត CPA2, លេខ3 តំណាងកំរិត CPA3, និង លេខ4 តំណាងកំរិត NH។ លេខកូដនឹងត្រូវប្រើជាពិសេសសំរាប់បច្ចេកវិទ្យាប្រព័ន្ធទំនាក់ទំនងព័ត៌មានសំរាប់សំរួលដល់ការត្រួតពិនិត្យតាមដានវាយតំលៃ ធ្វើរបាយការណ៍ និងដំណើរការទូទាត់ផ្សេងៗ។

**៣-ឈ្មោះករណី៖** (ជួរឈរលេខ៣ក្នុងតារាង) ឈ្មោះករណីនឹងត្រូវប្រើរួមគ្នាជាមួយលេខកូដសំរាប់គោលបំណងត្រួតពិនិត្យតាមដានវាយតំលៃ ធ្វើរបាយការណ៍ និងដំណើរការទូទាត់ផ្សេងៗដោយឡែក។

**៤-ការបរិយាយ/និយមន័យករណី៖** (ជួរឈរលេខ៤ក្នុងតារាង) ការបរិយាយ/និយមន័យ ករណីដែលមានលក្ខណៈស្របទៅនឹងការអនុវត្តន៍ជាក់ស្តែងអនុញ្ញាតឲ្យមូលដ្ឋានសុខា

ភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស កំណត់ និងបែងចែកករណីអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រទៅតាមប្រភេទករណីនីមួយៗ។

**៥-បញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យដែលពាក់ព័ន្ធ៖** (ជួរឈរលេខ៥ក្នុងតារាង) បញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ ដែលពាក់ព័ន្ធនានាប្រើសំរាប់ជាជំនួយបន្ថែមដល់មូលដ្ឋានសុខាភិបាលក្នុងការកំណត់ និងបែងចែកប្រភេទករណីក៏ដូចជាការធ្វើលំហាត់ ដើម្បីឈានឆ្ពោះទៅការអនុវត្តន៍យន្តការទូទាត់តាមប្រភេទរោគវិនិច្ឆ័យ (Diagnostic related group) ទៅថ្ងៃមុខ។

ដោយសារបញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យនេះ មិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយ មូលដ្ឋានសុខាភិបាលអាចប្រើតែការបរិយាយ/និយមន័យករណីសំរាប់កំណត់ប្រភេទករណីណាដែលស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ មិនមាននៅក្នុងបញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ។ សំរាប់ករណីសម្រាកពេទ្យ ការកំណត់ករណីនីមួយៗ នឹងត្រូវធ្វើឡើងនៅពេលអ្នកជំងឺចេញពីមន្ទីរពេទ្យ (ចេញដោយមានការអនុញ្ញាត ចេញដោយបញ្ជូន ឬ ចេញដោយស្លាប់)។សំរាប់ករណីដែលក្នុងរយៈពេលសម្រាកពេទ្យបានទទួលសេវាព្យាបាលថែទាំច្រើនផ្នែក នឹងត្រូវកំណត់ជាប្រភេទករណីមួយដែលមានតំលៃទូទាត់ខ្ពស់ជាងគេ។

ឧ. ករណីអ្នកជំងឺម្នាក់សម្រាកនៅផ្នែកសង្គ្រោះបន្ទាន់ រួចបន្តមកផ្នែកសល្យសាស្ត្រ និងចុងក្រោយត្រូវការវះកាត់ត្រូវចាត់ជាករណីវះកាត់ធំ និងទូទាត់តែសំរាប់ករណីវះកាត់ធំនេះទេ។

**៦-តំលៃទូទាត់៖** (ជួរឈរលេខ៦ក្នុងតារាង) តំលៃគិតជាប្រាក់រៀលដែល ប.ស.ស ត្រូវទូទាត់ឲ្យមូលដ្ឋានសុខាភិបាលសំរាប់ករណីនីមួយៗដែលបានកំណត់។ [1] តំលៃទូទាត់នេះគឺសម្រាប់គ្រប់សេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រទាំងអស់ដែលមូលដ្ឋានសុខាភិបាលចាំបាច់ ត្រូវផ្តល់ជូនសំរាប់ព្យាបាលថែទាំករណីជំងឺនោះតាមគោលការណ៍វិជ្ជាជីវៈ និងដែលមានចែងក្នុងតារាកាលិកដែលកំណត់ដោយប្រកាសស្តីពីតារាកាលិកថែទាំសុខភាព និងកិច្ចព្រមព្រៀងរវាងប.ស.ស និងមូលដ្ឋានសុខាភិបាល។ ប៉ុន្តែតំលៃទូទាត់នេះមិនរាប់បញ្ចូលថ្លៃសេវាបញ្ជូន និងថ្លៃសេវាអមវេជ្ជសាស្ត្រនានា ដែលមានចែងក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះទេ។ ចំពោះមូលដ្ឋានសុខាភិបាលឯកជន ប.ស.ស អាចទូទាត់ រហូតដល់

---

[1] *សូមបញ្ជាក់ថា តំលៃត្រូវទូទាត់នេះត្រូវបានគណនាផ្អែកលើតំលៃចំណាយដោយមិនគិតប្រាក់ឧបត្ថម្ភធនពីរាជរដ្ឋាភិបាលរបស់មណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋមួយចំនួនដែលបានមកពីការសិក្សាតំលៃមណ្ឌលសុខភាព និងមន្ទីរពេទ្យដែលបានធ្វើឡើងដោយក្រសួងសុខាភិបាលកន្លងមក ព្រមទាំងការលៃតម្រូវទៅតាមកំរិត ប្រើ ផ្ទៀងផ្ទាត់ជាមួយនឹងតំលៃហិរញ្ញប្បទាន និងតំលៃទូទាត់របស់មូលនិធិសមធម៌ ។*

១៥០% នៃតំលៃមូលដ្ឋានសុខាភិបាលសាធារណៈ ដោយផ្អែកតាមកំរិតសេវារបស់មូលដ្ឋានសុខាភិបាលឯកជននោះ ក្នុងករណីដែល ប.ស.ស មានការចាំបាច់ត្រូវចុះកិច្ចព្រមព្រៀងជាមួយ នៅទីតាំងដែលមិនមានសេវាសុខាភិបាលសាធារណៈសមស្រប។

ក្នុងការអនុវត្តន៍ជាក់ស្តែង ដើម្បីជំរុញការលើកកំពស់គុណភាពសេវា ប.ស.ស មានសិទ្ធិ ទូទាត់តិច ឬច្រើនជាងតំលៃត្រូវទូទាត់ដែលបានកំណត់ក្នុងតារាងនេះ (ចន្លោះពី ៨០% ទៅ ១២០%) ទៅតាមកំរិតគុណភាពសេវាដែលនឹងត្រូវវាស់វែង ឬ វាយតំលៃដោយយន្តការសមស្របមួយ។

**៧-ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាល៖** ដើម្បីអនុវត្តវិធីសាស្ត្រទូទាត់តាមករណីនេះ ប.ស.ស ត្រូវធ្វើការវាយតំលៃ និងចាត់ថ្នាក់មូលដ្ឋានសុខាភិបាល ដែលត្រូវចុះកិច្ចព្រមព្រៀងជាកំរិត MPA កំរិត CPA1 កំរិត CPA2 កំរិត CPA3 កំរិតចំរុះ ឬកំរិត NH ទៅតាមវិសាលភាព និងគុណភាពសេវារបស់មូលដ្ឋានសុខាភិបាលនោះ។ សូមបញ្ជាក់ថាមូលដ្ឋានសុខាភិបាលមួយ អាចទទួលកិច្ចព្រមព្រៀងសំរាប់សេវាច្រើនកំរិត (កំរិតចំរុះ)។ ឧ. សំរាប់មណ្ឌលសុខភាព មានគ្រែមួយ សេវាសម្រាកពេទ្យអាចចាត់ថ្នាក់ជាកំរិត CPA1 និងសេវាដទៃទៀតចាត់ថ្នាក់ជាកំរិត MPA។ មន្ទីរពេទ្យកំរិត CPA1 ខ្លះអាចមានសេវាវះកាត់ធំ។ ក្នុងករណីនេះសេវាវះកាត់ធំនេះអាចចាត់ថ្នាក់ជាកំរិត CPA2 បើទោះបីជាសេវាដទៃទៀតត្រូវបានចាត់ថ្នាក់ជាកំរិត CPA1 ក៏ដោយ។

សម្រាប់មណ្ឌលសុខភាពដែលមានទីតាំងនៅក្នុង ឬចំណុះការគ្រប់គ្រងរបស់មន្ទីរពេទ្យត្រូវចាត់ថ្នាក់ជាកំរិត MPA បើកំរិតសេវារបស់មណ្ឌលសុខភាពនោះគ្មានអ្វីខុសគ្នាពីមណ្ឌលសុខភាពដទៃទេនោះ។

| ល.រ | កូដ | ឈ្មោះករណី | ការបរិយាយ/និយមន័យករណី | ស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យដែលពាក់ព័ន្ធ | តំលៃទូទាត់ គិតជារៀល |
|---|---|---|---|---|---|
| 1 | CON0 | ករណីពិគ្រោះជំងឺក្រៅកំរិត MPA | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់ នៅមណ្ឌលសុខភាព។ សេវាពិគ្រោះជំងឺក្រៅរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ (ធ្វើតេស្តឈាមរកមេរោគគ្រុនចាញ់ និងធ្វើភ្នាសកំហាករកមេរោគរបេង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យ ចេញអោយប្រើ)<br>- ការពិនិត្យ និងព្យាបាលបន្តជំងឺរបេង ដូតឬហង់សិន ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ។ | - ជំងឺផ្តាសសាយទូទៅ (Common Cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវដែលមិនមានផលវិបាក (Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea Without Server Dehydration)<br>- ជំងឺគ្រុនចាញ់គ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ឬសង្ស័យរបេង/ឃ្លង់គ្មានផលវិបាក (Tuberculosis/leprosy or Suspected and Uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនគ្មានផលវិបាក (Uncomplicated Typhoid Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល ( Otitis Media )<br>- ជំងឺពុកធ្មេញ ( Dental Caries )<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ចង្កោមរោគសញ្ញាជំងឺកាមរោគ | ៥.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | (Sexual Transmitted Infection Syndrome)<br>- ជំងឺសើស្បែក (Skin disease)<br>- ឈឺក្បាល អស់កំលាំង ក្តៅខ្លួនមិនដឹងមូលហេតុ(Headache, Fatigue, Fever... of unknown origin)<br>- ជំងឺលើសឈាមគ្មានផលវិបាក (Uncomplicated Hypertension) ។ | |
| 2 | REFO | ករណីសង្គ្រោះបន្ទាន់ និងបញ្ជូនកំរិត MPA | ជាសេវាសង្គ្រោះបឋម និងការបញ្ជូនចេញពីមណ្ឌលសុខភាព ដោយគិតរួមបញ្ចូលទាំង៖<br>- លិខិតបញ្ជូន<br>- ការបញ្ចូលសេរ៉ូម<br>- សេវាសង្គ្រោះបឋមក្នុងពេលបញ្ជូន<br>- ការពិនិត្យតាមដានចាំបាច់ដទៃទៀតតែមិនគិតរួមបញ្ចូលថ្លៃដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងៗទេ។ | - ជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរដូចជា៖ ជំងឺរលាកសួត ឬជំងឺហឺត ( Pneumonia/Asthma)<br>- ជំងឺរាគរ៉ាំរ៉ៃ ឬជំងឺរាគមានការបាត់បង់ជាតិទឹកធ្ងន់ធ្ងរ(Chronic Diarrhea or Diarrhea with Severe Dehydration)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ(Complicated Malaria)<br>- សង្ស័យជំងឺរបេងសួត ឬ របេងក្រៅសួតធ្ងន់ធ្ងរ (Suspected Severe Pulmonary/ Extra-pulmonary Tuberculosis )<br>- ជំងឺគ្រុនពោះវៀនមានផលវិបាក (Complicated Typhoid Fever)<br>- សង្ស័យជំងឺគ្រុនឈាម (Suspected Dengue Fever) | ១០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ការសម្រាលកូនពិបាក (Complicated Delivery)<br>- លង់ទឹក (Drown)<br>- ស្តុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- បាក់ឆ្អឹង (Bone Fracture)<br>- រលាក ឬ ហូរឈាមធ្ងន់ធ្ងរ (Severe Burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ឆ្កែខាំ (Dog Bite)<br>- សត្វទិច/ខាំ ដែលអាចបង្កអោយមានគ្រោះថ្នាក់<br>- ស្ថានភាពវេជ្ជសាស្ត្រសុត្រស្មាញផ្សេងទៀត ដែលមណ្ឌលសុខភាព មិនមានលទ្ធភាពពិនិត្យព្យាបាល ។ | |
| 3 | MIN0 | ករណីវះកាត់តូច កំរិត MPA | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖ | - បូសធម្មតា ( Cutaneous Abscess )<br>- របួសតូច ( Small Wound ) | |

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំស្ពឹក ( Local Anesthesia )<br>- ការវះកាត់<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀត សម្រាប់ករណីសល្យសាស្ត្រតូចនៅមណ្ឌលសុខភាព។ | - រលាកស្រាល ( Mild Burn ) ។ | |
| 4 | PREO | ករណីសេវាបង្ការ និងពន្យារកំណើតរយៈពេលខ្លី កំរិត MPA | - ជាការពន្យារកំណើតករណីថ្មី និងករណីបន្តបន្ទាប់ (រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ដូចជា ស្រោមអនាម័យ ថ្នាំគ្រាប់ឬថ្នាំចាក់)<br>- ការពិនិត្យផ្ទៃពោះមុនសំរាល (រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត)<br>- ការពិគ្រោះក្រោយសំរាល<br>- ការព្យាបាលថែទាំក្រោយរលូត | - ការថែទាំមុនសំរាល (Antenatal Care)<br>- ការពន្យារកំណើត (Birth Spacing)<br>- ការថែទាំក្រោយសំរាល (Postnatal Care)<br>- ការព្យាបាលថែទាំក្រោយរលូត (Postabortion Care)<br>- ការចាក់ថ្នាំបង្ការ ( Vaccination )។ | ១០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំបង្ការនៅ មណ្ឌលសុខភាព។ | | |
| 5 | BSL0 | សេវាពន្យារកំណើតរយៈពេលវែង កំរិត MPA | ជាការពន្យារកំណើតសម្រាប់ករណីថ្មី និងករណីបន្តបន្ទាប់ ដោយរួមបញ្ចូលៈ<br>- ការដាក់កងក្នុងស្បូន ឬ ដាក់កងក្នុងដៃស្បូន<br>- ការប្រឹក្សាពីវិធីសាស្ត្រពន្យារកំណើតនៅមណ្ឌលសុខភាព។ | - ការពន្យារកំណើតរយៈពេលវែង ( Prolonged Birth Spacing)។ | ២០.០០០ |
| 6 | DEL0 | ករណីសំរាលកូន កំរិត MPA | ជាការសំរាល និងសេវាចាំបាច់ដទៃទៀត រួមមានៈ<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រង ការសំរាលសកម្មដំណាក់កាលទី៣ (AMTSL)<br>- ការដេរស្នាមកាត់ឬដាច់ទ្វារមាស<br>- ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសំរាប់ករណីសំរាលកូនធម្មតា នៅ | - ការសំរាលកូនធម្មតា (Normal delivery)។ | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មណ្ឌលសុខភាព។ | | |
| 7 | CON1 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA1 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន (Referral consultations) នៅមន្ទីរពេទ្យបង្អែកកម្រិត១។សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ ( សេវាមន្ទីរពិសោធន៍មូលដ្ឋាន អេកូសាស្ត្រ ការថតកាំរស្មីអ៊ិច ការវាស់អគ្គិសនីបេះដូង)<br>- កាព្យាបាលនិងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាបញ្ជូនបន្ទាន់សម្រាប់អ្នកជំងឺក្រៅ ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ (ដោយមិនគិតថ្លៃសេវា | - ជំងឺផ្តាសសាយទូទៅ (Common Cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវ ដែលមិនមានផលវិបាក(Uncomplicated Acute Respiratory Infections)<br>- រាគមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់គ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ឬសង្ស័យរបេង/ឃ្លង់ គ្មានផលវិបាក(Tuberculosis/Leprosy or Suspected uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនគ្មានផលវិបាក ( Uncomplicated Typhoid Fever )<br>- ជំងឺគ្រុនឈាមគ្មានផលវិបាក ( Uncomplicated Dengue Fever )<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis)<br>- រលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ (Dental Caries) | ៨.០០០ |



IK

| | | | | | |
|---|---|---|---|---|---|
| | | | ដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងៗទេ)។ | - ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ចង្កោមរោគសញ្ញាជំងឺកាមរោគ(Sexually Transmitted Infection Syndrome)<br>- ជំងឺសើស្បែក (Skin Disease)<br>- ឈឺក្បាល អស់កំលាំង ក្តៅខ្លួនមិនដឹងមូលហេតុ ( Headache, Fatigue, Fever... of Unknown Origin)<br>- ស្ថានភាពដទៃទៀតដែលមិនអាចគ្រប់គ្រងបាននៅមណ្ឌលសុខភាព ប៉ុន្តែមិនត្រូវការសម្រាកពេទ្យ។<br>- ករណីបញ្ជូនបន្ទាន់រួមមាន៖<br>• រលាកស្រោមខួរក្បាល គិតរួមទាំងរលាកស្រោមខួរក្បាល ដោយមេរោគរបេង (Meningitis Including Tuberculosis Meningitis)<br>• រលាកខួរក្បាល ( Encephalitis )<br>• របេងសួតទំរង់ធ្ងន់ធ្ងរ (MiliaryTuberculosis)<br>• តេតាណូស (Tetanus )<br>• ស្ថានភាពវេជ្ជសាស្ត្រដូចមានថែងក្នុង | |



IK

| | | | | | |
|---|---|---|---|---|---|
| | | | | ប្រភេទករណី EMG1 ដែលត្រូវការបញ្ជូនបន្ទាន់។ | |
| 8 | MIN1 | ករណីវះកាត់តូចកំរិត CPA1 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក ( Local Anesthesia)<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និង ការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ (Superficial Abscess)<br>- របួសតូច (Small Wound)<br>- រលាកកំរិតស្រាល (Mild Burn)<br>- រលាកសាច់ដុំកំរិតមធ្យម (Moderate Myositis)<br>- គីសស្បែក (Sebaceous Cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលឹង្គ (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ ( Tooth Extraction )។ | ១៦.០០០ |
| 9 | EMG1 | ករណីសង្គ្រោះបន្ទាន់កំរិត CPA1 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬ អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកកម្រិត១ដោយសំរាក | ស្ថានភាពវេជ្ជសាស្ត្រណាក៏ដោយ ដែលត្រូវការសង្គ្រោះជីវិតបន្ទាន់រួមមាន៖<br>- លង់ទឹក (Drown)<br>- វិបត្តិដង្ហើម (Respiratory Distress )<br>- ស្លុក ( Shock) | ១២០.០០០ |



ﾅ

| | | | | | |
|---|---|---|---|---|---|
| | | | ពេទ្យ។ | - ប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាក ឬហូរឈាមធ្ងន់ធ្ងរ (Severe burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ(Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍(ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យឬសម្រាកពេទ្យ)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀត ដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 10 | MED1 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យបង្អែកកម្រិត១ ។ ករណីសម្រាកពេទ្យផ្នែកសល្យសាស្ត្រដែលមិនត្រូវការសង្គ្រោះបន្ទាន់ ឬបញ្ជូនដូចជារលាកភ្លើង ឬរបួស ត្រូវចាត់ចូលក្នុងប្រភេទករណីនេះ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត ( Asthma )<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន(Typhoid Fever)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់(Arthropathy)<br>- ស្ថានភាពវេជ្ជសាស្រ្តដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 11 | DEL1 | ករណីសំរាលកូនកំរិត CPA1 | ជាការសំរាល និងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលស្បៀម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ | - ការសំរាលធម្មតា( Normal Delivery)<br>- ការសំរាលពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ។ | ៨៤,០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | នៃការគ្រប់គ្រងការសំរាលសកម្ម ដំណាក់កាលទី៣(AMTSL)<br>- ការបូមយកកូន<br>- ការដេរស្នាមកាត់ ឬដាច់ទ្វារមាស<br>- ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំ និងសង្គ្រោះទារក នៅពេលកើតភ្លាម<br>- ការថែទាំ និងតាមដានក្រោយសំ-រាល សម្រាប់ការសំរាលធម្មតា ឬមានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | | |
| 12 | GYN1 | ករណីរោគស្ត្រី កំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រី នៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - រលាកមាត់ស្បូនធ្ងន់ធ្ងរ(Severe Cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina Wound or Injury)។ | ៩២.០០០ |
| 13 | ABO1 | ករណីរលូត/រំលូតកូនកំរិត CPA1 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយ សុវត្ថិភាព ព្រមទាំងការថែទាំ ក្រោយរំលូត/រលូតកូនដោយឯកឯង នៅមន្ទីរពេទ្យបង្អែក | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still Birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬការពពោះដែលមិនសមស្របតាមផ្ទៃក | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | កម្រិត១។ | វេជ្ជសាស្ត្រ។ | |
| 14 | PED1 | ករណីជំងឺទូទៅកុមារកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ដោយផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត(Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬផ្តល់ផលវិបាក ( Severe/Complicated Malaria )<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | ៧២.០០០ |

| | | | | | |
|---|---|---|---|---|---|
| 15 | TUB1 | ករណីជំងឺរបេងកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ត្រូវផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All Forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-Pulmonary Tuberculosis)<br>- លើកលែងតែរលាកស្រោមខួរក្បាលដោយមេរោគរបេង (Tuberculous Meningitis) របេងសួតទំរង់ធ្ងន់ធ្ងរ (Miliary Tuberculosis) ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | ១៦០.០០០ |
| 16 | CON2 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA2 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់ រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសកំរិតមូលដ្ឋាន នៅមន្ទីរពេទ្យបង្អែកកម្រិត២។ សេវាពិគ្រោះរួមមានៈ<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវា | - ជំងឺផ្តាសសាយទូទៅ (Common Cold)<br>- ជំងឺឆ្លងផ្លូវដង្ហើមស្រួចស្រាវដែលគ្មានផលវិបាក(Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក(Suspected and Uncomplicated Tuberculosis/leprosy) | ១២.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាបញ្ជូនបន្ទាន់សម្រាប់អ្នកជំងឺក្រៅ ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ (ដោយមិនគិតថ្លៃសេវាដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងទេ)។ | - ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early Detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ ( Acute Conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ ( Dental Caries )<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ (Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយមិនដឹងមូលហេតុ (Headache, Fatigue, Fever...of Unknown Origin)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus )<br>- ជំងឺអេដស៍ (អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំង និងមេរោគអេដស៍ OI/ART) ( HIV/AIDS ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental illness )<br>- បញ្ហាសុខភាពមាត់ធ្មេញ (Oral Health | |

| | | | | | |
|---|---|---|---|---|---|
| | | | | problem)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងៗទៀត ដែលមិនអាចព្យាបាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកកំរិត១ ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ។<br>- ករណីបញ្ជូនបន្ទាន់គឺសំដៅលើរាល់ស្ថានភាពវេជ្ជសាស្ត្រ ដូចមានចែងក្នុងប្រភេទករណី EMG2 ដែលត្រូវការបញ្ជូនបន្ទាន់។ | |
| 17 | MIN2 | ករណីវះកាត់តូចកំរិត CPA2 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia)<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរ | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ(Superficial Abscess )<br>- របួសតូច (Small wound)<br>- រលាកស្រាល/មធ្យម (Mild/Moderate Burn )<br>- រលាកសាច់ដុំ (Myositis)<br>- ដុំពកជាទឹក(គីសស្បែក) (Sebaceous Cyst)<br>- ដុំពកជាខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth Extraction)។ | ២០.០០០ |



115

| | | | | | |
|---|---|---|---|---|---|
| | | | ពេទ្យបង្អែកកម្រិត២។ | | |
| 18 | EMG2 | ករណីសង្គ្រោះបន្ទាន់កំរិត CPA2 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកកម្រិត២ដោយសំរាកពេទ្យ។ | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន៖<br>- ករណីលង់ទឹក (Drown)<br>- វិបត្តិដង្ហើម (Respiratory Distress )<br>- ស្តុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាក ឬហូរឈាមធ្ងន់ធ្ងរ (Severe burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ(Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ )<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់/ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe Chest Pain) | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺតេតាណូស (Tetanus)<br>- ជំងឺហើមសួតស្រួចស្រាវ (Acute Pulmonary Edema)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់ ។ | |
| 19 | SUR2 | ករណីសល្យសាស្ត្រកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ(លើកលែងករណីវះកាត់ធំដូចមានចែងក្នុង MAJ2) នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ការប៉ះទង្គិចក្បាល (Head Trauma)<br>- ការប៉ះទង្គិចពោះ (Abdominal Trauma)<br>- ការប៉ះទង្គិចទ្រូង (Chest Trauma)<br>- របួសហូរឈាមក្នុងពោះ ( Intra-abdominal Hemorrhage )<br>- ជំងឺបូសថ្លើម ( Liver Abscess)<br>- គ្រួសក្នុងតំរងនោម (Kidney Stone)<br>- គ្រួសក្នុងប្លោកនោម (Bladder Stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់(Gallbladder Stone)។ | ១២០.០០០ |
| 20 | MAJ2 | ករណីវះកាត់ធំកំរិត CPA2 | ជាអន្តរាគមន៍សល្យសាស្ត្រធំ ធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ ដោយរួម | - ជំងឺរលាកខ្នែងពោះវៀន (Appendicitis)<br>- ជំងឺក្លូន (Hernia)<br>- កូនក្រៅស្បូន (Ectopic Pregnancy)<br>- គីស/ដុំអូវែរ (Ovarian Cyst/Tumor)<br>- កាត់អវៈយវៈ (Amputation)<br>- វះកាត់ភ្នែក ( ភ្នែកឡើងបាយ ភ្នែករបួស ) | ២៩០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត២។ | (Ophthalmic Surgery including Cataract, Eye Injury )<br>- វះកាត់យកកូនចេញ(ករណីសំរាលតាមទ្វាមាសមិនបាន) ( Caesarian Section)<br>- ភ្លាត់សន្លាក់ (Dislocation of Joint)<br>- ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន/ចងបំពង់មេជីវិតបុរស) (Sterilization by tuboligation / vasectomy)។ | |
| 21 | MED2 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្ដល់ដោយផ្នែកជំងឺទូទៅ នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត ( Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្ដល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក | ១០០.០០០ |



115

| | | | | | |
|---|---|---|---|---|---|
| | | | | (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ ( Gastric Ulcer)<br>- ជំងឺរលាកស្រោមបេះដូងនិងជំងឺបេះដូងផ្សេងៗ (Pericarditis and Other forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus )<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត (Thyroid Gland Disease)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 22 | DEL2 | ករណីសំរាលកូនកំរិត CPA2 | ជាការសំរាល និងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម | - ការសំរាលកូនធម្មតា(Normal Delivery)<br>- ការសំរាលកូនពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ។ | |



ℓ೨

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣ (AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬដាច់ទ្វារមាស<br>- ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | | |
| 23 | GYN2 | ករណីរោគស្ត្រីកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រី នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - រលាកមាត់ស្បូនធ្ងន់ធ្ងរ(Severe Cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina Wound/Injury)។ | ១២០.០០០ |
| 24 | ABO2 | ករណីរលូត/រំលូតកូនកំរិត CPA2 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំង | - រលូតកូន (Miscarriage )<br>- កូនស្លាប់ក្នុងពោះ (Still Birth) | ៥០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ការពពោះដែលមិនតាមបំណងប្រាថ្នាឬការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | |
| 25 | PED2 | ករណីជំងឺទូទៅកុមារកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ដោយផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត២ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion )<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/ leprosy )<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS) | ៨៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម(Septicemia)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 26 | TUB2 | ករណីជំងឺរបេងកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ត្រូវផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All Forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis)<br>- លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ ជំងឺឃ្លង់ដែលត្រូវការសម្រាកពេទ្យ។ | ១៨០.០០០ |
| 27 | CON3 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA3 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសគ្រប់កំរិតនៅមន្ទីរពេទ្យបង្អែកកម្រិត៣ សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព | - ជំងឺផ្តាសសាយទូទៅ (Common Cold )<br>- ជំងឺឆ្លងផ្លូវដង្ហើមស្រួចស្រាវ ដែលគ្មានផលវិបាក (Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក (Suspected and Uncomplicated | ១៦.០០០ |



115

| | | | | | |
|---|---|---|---|---|---|
| | | | - ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវាមន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង អេកូបេះដូង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)។<br>- សេវាអមវេជ្ជសាស្ត្រដែលមានតំលៃខ្ពស់ ដូចជា CT-Scan, MRI, EEG មិនគិតរួមបញ្ចូលក្នុងករណីនេះទេ។ | Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early Detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ (Dental Caries)<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ(Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយគ្មានមូលហេតុ (Headache , Fatigue ,Fever... of Unknown Origin)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺអេដស៍(អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំងនិងមេរោគអេដស៍ OI/ART) (HIV/AIDS Ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental illness )<br>- ជំងឺផ្សេងៗទៀតដែលមិនអាចពិគ្រោះ | |

| | | | | | |
|---|---|---|---|---|---|
| | | | | ព្យាបាលនៅថ្នាក់ក្រោមបាន គិតទាំងការថែទាំជំងឺឯកទេសគ្រប់ប្រភេទផ្នែកទន្តសាស្ត្រ ចក្ខុសាស្ត្រ ត្រចៀក/ច្រមុះ/បំពង់ក និងផ្លូវចិត្ត ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ ។ | |
| 28 | MIN3 | ករណីវះកាត់តូច កំរិត CPA3 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia )<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ (Superficial Abscess)<br>- របួសតូចតាច (Small Wound)<br>- រលាកស្រាល/មធ្យម(Mild/Moderate Burn)<br>- រលាកសាច់ដុំ (Myositis)<br>- គីសស្បែក (Sebaceous Cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ(ស្បែកបាំងចុងប្រដាប់ភេទបុរសទាំងមូលឬមួយផ្នែក) (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth Extraction )។ | ២៤.០០០ |
| 29 | EMG3 | ករណីសង្គ្រោះបន្ទាន់កំរិត CPA3 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជ-សាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណា | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន៖ | [illegible] |

| | | | | | |
|---|---|---|---|---|---|
| | | | មួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យបង្អែកកម្រិតព ដោយសំរាកពេទ្យ។ | - ករណីលង់ទឹក (Drown )<br>- វិបត្តិដង្ហើម (Respiratory Distress)<br>- ស្កុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាកឬហូរឈាមធ្ងន់ធ្ងរ (Severe Burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ( Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ)<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe Chest Pain)<br>- ជំងឺតេតាណូស (Tetanus )<br>- ជំងឺហើមសួតស្រួចស្រាវ ( Acute Pulmonary Edema) | |

| | | | | | |
|---|---|---|---|---|---|
| | | | | - ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 30 | SUR3 | ករណីសល្យសាស្ត្រកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ (លើកលែងករណីវះកាត់ធំដូចមានចែងក្នុងMAJ3) នៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ការប៉ះទង្គិចក្បាល (Head Trauma)<br>- ការប៉ះទង្គិចពោះ (Abdominal Trauma)<br>- ការប៉ះទង្គិចទ្រូង (Chest Trauma)<br>- របួសហូរឈាមក្នុងពោះ(Intra-abdominal Hemorrhage)<br>- បូសថ្លើម (Liver Abscess)<br>- គ្រួសក្នុងតំរងនោម (Kidney Stone)<br>- គ្រួសក្នុងប្លោកនោម (Bladder Stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់(Gallbladder Stone)។ | ១៦០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 31 | MAJ3 | ករណីវះកាត់ធំកំរិត CPA3 | ជាអន្តរាគមន៍សល្យសាស្ត្រធំធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ជំងឺរលាកខ្នែងពោះវៀនគិតទាំងអាប់សែខ្នែងពោះវៀន (Appendicitis Including Appendicular Abscess)<br>- ជំងឺក្លូន(គិតទាំងក្លូនចុក) (Hernia including Complicated or Strangulated)<br>- កូនក្រៅស្បូន (Ectopic Pregnancy)<br>- គីស/ដុំអូវែ (Ovarian Cyst/Tumor )<br>- រលាកស្រោមពោះ (Peritonitis)<br>- ការវះកាត់តំរងនោម (គ្រោះក្នុងតំរងនោម ឬជំងឺតំរងនោមដោយមូលហេតុផ្សេងៗ) (Renal Surgery including Kidney stone or other causes)<br>- ការវះកាត់ក្រពេញប្រូស្តាត(ដំពក ឬមហារីកប្រូស្តាត) (Prostate Gland Surgery including Prostate Tumor Or Cancer)<br>- ការវះកាត់ប្លោកនោម (គ្រោះក្នុងប្លោកនោម ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺប្លោកនោម) (Bladder Surgery including Bladder stone or | ៤០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | other causes)<br>- ការវះកាត់ថង់ទឹកប្រមាត់(គ្រោះក្នុងថង់ទឹកប្រមាត់ ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺថង់ទឹកប្រមាត់) (Gallbladder Surgery including Gallbladder Stone and Other causes)<br>- ការវះកាត់ស្បូន ( ការធ្លាយស្បូន ជំងឺស្រុតស្បូន ដុំសាច់ស្បូន) (Uterus Surgery including Uterus Rupture, Prolapse, Tumor)<br>- ការវះកាត់ដុំពោះ (Abdominal Tumor Surgery)<br>- ការវះកាត់ក្រពេញទីរ៉ូអ៊ីត(ជំងឺក្រពេញទីរ៉ូអ៊ីតមានផលវិបាក) (Thyroid Gland Surgery including Complicated Thyroid disease)<br>- ការវះកាត់ពោះវៀន ( ការស្ទះពោះវៀន , របួសពោះវៀន) (Intestinal Surgery including Intestinal Occlusion, Intestinal Injury)<br>- ការវះកាត់អវៈយវៈ ឬការវះកាត់ឆ្អឹងផ្សេង | |

| | | | | | |
|---|---|---|---|---|---|
| | | | | ទៀត(ការបាក់ឆ្អឹង) (Amputation and other Orthopedic Surgical interventions (Bone Fracture)<br>- ការវះកាត់ភ្នែក(ភ្នែកឡើងបាយ របួសភ្នែក) (Ophthalmic Surgery including Cataract, Eye Injury)<br>- ការវះកាត់យកកូនចេញ (Caesarian Section)<br>- ការវះកាត់ធំផ្នែកត្រចៀក/ច្រមុះ/បំពង់ក ( E-N-T Major Surgery )<br>- ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន ចងបំពង់មេជីវិតបុរស) (Sterilization by Tuboligation/Vasectomy)។ | |
| 32 | MED3 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea) | ១២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer )<br>- ហូរឈាមខាងក្នុងពោះ (Intra-abdominal Hemorrhage)<br>- ជំងឺរលាកស្រោមបេះដូង និងជំងឺបេះដូងផ្សេងៗ (Pericarditis and Other Forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus)<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត(Thyroid Gland Disease) | |

| | | | | | |
|---|---|---|---|---|---|
| | | | | - ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 33 | DEL3 | ករណីសំរាលកូនកំរិត CPA3 | ជាការសំរាលកូននិងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣ (AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬ ដាច់ទ្វារមាស ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំនិងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត ៣ ។ | - ការសំរាលកូនធម្មតា (Normal delivery)<br>- ការសំរាលកូនពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ ។ | ១២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 34 | GYN3 | ករណីរោគស្ត្រីកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រីនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - រលាកទ្វារមាសធ្ងន់ធ្ងរ (Severe Cervicitis )<br>- គ្រោះថ្នាក់របួសទ្វារមាស (Vagina Wound/Injury)<br>- ជំងឺមហារីកមាត់ស្បូន (Cervical Cancer)<br>- ជំងឺមហារីកដោះ (Breast Cancer) | ១៦០.០០០ |
| 35 | ABO3 | ករណីរលូត/រំលូតកូនកំរិត CPA3 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅមន្ទីរពេទ្យបង្អែកកម្រិត ៣ ។ | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still Birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬ ការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | ១០០.០០០ |
| 36 | PED3 | ករណីជំងឺទូទៅកុមារកំរិត CPA3 | ជាការសម្រាកពេទ្យសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ជូននៅផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត( Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe Or Chronic Diarrhea) | ១០៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 37 | TUB3 | ករណីជំងឺរបេងកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ដែលផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis)<br>- លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ(Except Multidrug Resistant Forms) | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | |
| 38 | CON4 | ករណីពិគ្រោះជំងឺក្រៅកំរិត NH | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសគ្រប់កំរិតនៅមន្ទីរពេទ្យជាតិសេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវាមន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង អេកូបេះដូង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)។<br>- សេវាអមវេជ្ជសាស្ត្រដែលមានតំលៃខ្ពស់ ដូចជា CT-Scan, MRI, EEG | - ជំងឺផ្តាសសាយទូទៅ (Common Cold )<br>- ជំងឺឆ្លងផ្លូវដង្ហើមស្រួចស្រាវ ដែលគ្មានផលវិបាក (Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក (Suspected and Uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early Detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis) | ២៤.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មិនគិតរួមបញ្ចូលក្នុងករណីនេះទេ។ | - ជំងឺរលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ (Dental Caries)<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ(Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយគ្មានមូលហេតុ (Headache , Fatigue ,Fever... of Unknown Origin)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺអេដស៍(អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំងនិងមេរោគអេដស៍ OI/ART) ( HIV/AIDS Ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental illness )<br>- ជំងឺផ្សេងៗទៀតដែលមិនអាចពិគ្រោះព្យាបាលនៅថ្នាក់ក្រោមបាន គិតទាំងការថែទាំជំងឺឯកទេសគ្រប់ប្រភេទផ្នែកទន្តសាស្រ្ត ចក្ខុសាស្រ្ត ត្រចៀក/ច្រមុះ/បំពង់ក និងផ្លូវចិត្ត ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ ។ | |
| 39 | MIN4 | ករណីវះកាត់តូច កំរិត NH | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia ) | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ (Superficial Abscess)<br>- របួសតូចតាច (Small Wound) | |

| | | | | | |
|---|---|---|---|---|---|
| | | | - ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅ មន្ទីរពេទ្យជាតិ។ | - រលាកស្រាល/មធ្យម(Mild/Moderate Burn)<br>- រលាកសាច់ដុំ (Myositis)<br>- គីសស្បែក (Sebaceous Cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ(ស្បែកបាំងចុងប្រដាប់ភេទបុរសទាំងមូលឬមួយផ្នែក) (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth Extraction )។ | |
| 40 | EMG4 | ករណីសង្គ្រោះបន្ទាន់កំរិត NH | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជ-សាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ ជាតិ ដោយសំរាកពេទ្យ។ | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន៖<br>- ករណីលង់ទឹក (Drown )<br>- វិបត្តិដង្ហើម (Respiratory Distress)<br>- ស្ហុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាកឬហូរឈាមធ្ងន់ធ្ងរ (Severe Burn or Hemorrhage) | ៦០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ( Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ)<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe Chest Pain)<br>- ជំងឺតេតាណូស (Tetanus )<br>- ជំងឺហើមសួតស្រួចស្រាវ ( Acute Pulmonary Edema)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 41 | SUR4 | ករណីសល្យសាស្ត្រកំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ (លើកលែងករណីវះកាត់ធំដូចមានចែងក្នុងMAJ4) | - ការប៉ះទង្គិចក្បាល (Head Trauma)<br>- ការប៉ះទង្គិចពោះ (Abdominal Trauma)<br>- ការប៉ះទង្គិចទ្រូង (Chest Trauma)<br>- របួសហូរឈាមក្នុងពោះ(Intra-abdominal | ៣០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | នៅ មន្ទីរពេទ្យជាតិ។ | Hemorrhage)<br>- បូសថ្លើម (Liver Abscess)<br>- គ្រួសក្នុងតំរងនោម (Kidney Stone)<br>- គ្រួសក្នុងប្លោកនោម (Bladder Stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់(Gallbladder Stone)។ | |
| 42 | MAJ4 | ករណីវះកាត់ធំ កំរិត NH | ជាអន្តរាគមន៍សល្យសាស្ត្រធំធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកខ្នែងពោះវៀនគិតទាំងអាប់សែខ្នែងពោះវៀន (Appendicitis Including Appendicular Abscess)<br>- ជំងឺក្លូន(គិតទាំងក្លូនចុក) (Hernia including Complicated or Strangulated)<br>- កូនក្រៅស្បូន (Ectopic Pregnancy)<br>- គីស/ដុំអូវែរ (Ovarian Cyst/Tumor )<br>- រលាកស្រោមពោះ (Peritonitis)<br>- ការវះកាត់តំរងនោម (គ្រោះក្នុងតំរងនោម ឬជំងឺតំរងនោមដោយមូលហេតុផ្សេងៗ) (Renal Surgery including Kidney stone or other causes)<br>- ការវះកាត់ក្រពេញប្រូស្តាត(ដំពក | ១.០០០.០០០ |



Hh. M

HS

| | | | | | |
|---|---|---|---|---|---|
| | | | | ឬមហារីកប្រូស្តាត) (Prostate Gland Surgery including Prostate Tumor Or Cancer)<br>- ការវះកាត់ប្លោកនោម (គ្រោះក្នុងប្លោកនោម ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺប្លោកនោម) (Bladder Surgery including Bladder stone or other causes)<br>- ការវះកាត់ថង់ទឹកប្រមាត់(គ្រោះក្នុងថង់ទឹកប្រមាត់ ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺថង់ទឹកប្រមាត់) (Gallbladder Surgery including Gallbladder Stone and Other causes)<br>- ការវះកាត់ស្បូន ( ការធ្លាយស្បូន ជំងឺស្រុតស្បូន ដុំសាច់ស្បូន) (Uterus Surgery including Uterus Rupture, Prolapse, Tumor)<br>- ការវះកាត់ដុំពោះ (Abdominal Tumor Surgery)<br>- ការវះកាត់ក្រពេញទីរ៉ូអ៊ីត(ជំងឺក្រពេញទីរ៉ូអ៊ី | |

| | | | | | |
|---|---|---|---|---|---|
| | | | | តមានផលវិបាក) (Thyroid Gland Surgery including Complicated Thyroid disease)<br>- ការវះកាត់ពោះវៀន ( ការស្ទះពោះវៀន , របួសពោះវៀន) (Intestinal Surgery including Intestinal Occlusion, Intestinal Injury)<br>- ការវះកាត់អវៈយវៈ ឬការវះកាត់ឆ្អឹងផ្សេងទៀត(ការបាក់ឆ្អឹង) (Amputation and other Orthopedic Surgical interventions (Bone Fracture)<br>- ការវះកាត់ភ្នែក(ភ្នែកឡើងបាយ របួសភ្នែក) (Ophthalmic Surgery including Cataract, Eye Injury)<br>- ការវះកាត់យកកូនចេញ (Caesarian Section)<br>- ការវះកាត់ធំផ្នែកត្រចៀក/ច្រមុះ/បំពង់ក ( E-N-T Major Surgery ) | |
| 43 | PRE4 | ករណីវះកាត់មធ្យមកំរិត NH | ជាអន្តរាគមន៍សល្យសាស្ត្រធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំ | - ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន ចងបំពង់មេជីវិតបុរស) (Sterilization by Tuboligation/Vasectomy)។ | ៤០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ស្តីកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យជាតិ។ | | |
| 44 | MED4 | ករណីជំងឺទូទៅ មនុស្សពេញវ័យ កំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS) | ៣០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer )<br>- ហូរឈាមខាងក្នុងពោះ (Intra-abdominal Hemorrhage)<br>- ជំងឺរលាកស្រោមបេះដូង និងជំងឺបេះដូងផ្សេងៗ (Pericarditis and Other Forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus)<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត(Thyroid Gland Disease)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 45 | DEL4 | ករណីសំរាលកូនកំរិត NH | ជាការសំរាលកូននិងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ | - ការសំរាលកូនធម្មតា (Normal delivery)<br>- ការសំរាលកូនពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ ។ | ៤០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | នៃការគ្រប់គ្រងការសំរាលសកម្ម ដំណាក់កាលទី៣ (AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬ ដាច់ទ្វារមាស ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំនិងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅ ឬមន្ទីរពេទ្យជាតិ។ | | |
| 46 | GYN4 | ករណីរោគស្ត្រី កំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រីនៅ មន្ទីរពេទ្យជាតិ។ | - រលាកទ្វារមាសធ្ងន់ធ្ងរ (Severe Cervicitis )<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina Wound/Injury)<br>- ជំងឺមហារីកមាត់ស្បូន (Cervical Cancer)<br>- ជំងឺមហារីកដោះ (Breast Cancer) | ៣០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 47 | ABO4 | ករណីរលូត/រំលូតកូនកំរិត NH | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅ មន្ទីរពេទ្យជាតិ។ | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still Birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬ ការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | ២០០.០០០ |
| 48 | PED4 | ករណីជំងឺទូទៅកុមារកំរិត NH | ជាការសម្រាកពេទ្យសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ជូននៅផ្នែកជំងឺកុមារនៅមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត( Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe Or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever) | ៣០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 49 | TUB4 | ករណីជំងឺរបេងកំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ដែលផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យជាតិ។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis)<br>- លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ(Except Multidrug Resistant Forms) ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | ៣០០.០០០ |

*ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*

## វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា

ឧបសម្ព័ន្ធនេះមានគោលបំណងរៀបចំវិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា សម្រាប់ករណីពិសេសតាមតារាងតម្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ របស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ផ្នែកថែទាំសុខភាព។

ក. **វិធីសាស្ត្រនេះត្រូវអនុវត្តចំពោះប្រភេទករណីដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬសេវាព្យាបាលនិងថែទាំបន្ត និងករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធទី១**

**ក.១ ប្រភេទករណីដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬ សេវាព្យាបាល និងថែទាំបន្តដូចខាងក្រោម៖**

**ក.១.១ ការលាងឈាម** គឺជាការលាងឈាមបណ្តាលមកពីឧបទ្ទវហេតុគ្រោះថ្នាក់ផ្សេងៗ ឬសង្គ្រោះបន្ទាន់ ។

***ចំពោះករណីលាងឈាមតាមការគ្រោងទុកដែលបណ្តាលមកពីជំងឺរ៉ាំរ៉ៃ មិនត្រូវបានរាប់បញ្ចូលឡើយ។***

**ក.១.២ MRI (Magnetic Resonance Imaging)** គឺជាបច្ចេកទេសរូបភាពវេជ្ជសាស្ត្រដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពទៅតាមស្ថានភាពចាំបាច់ និងមនសិការវិជ្ជាជីវៈ។

**ក.១.៣ CT SCAN** គឺជាទម្រង់រូបភាពវេជ្ជសាស្ត្រដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពតាមស្ថានភាពចាំបាច់ និងមនសិការវិជ្ជាជីវៈ។

**ក.១.៤ ការព្យាបាលដោយកាំរស្មីអ៊ិច** (Radiotherapy) គឺជាការព្យាបាលជំងឺមហារីកដោយកាំរស្មីអ៊ិចផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពតាមបច្ចេកទេសវេជ្ជសាស្ត្រ។

**ក.១.៥ ការវិភាគរកកោសិកាមហារីក** គឺជាការវិភាគចំណិតដុំសាច់នៃសរីរាង្គឬផ្នែកណាមួយនៃរាងកាយដើម្បីរកកោសិកាមហារីក ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។

ក.១.៦ MATERIEL OSTEOSYNTHESE គឺជាលោហៈដែលប្រើប្រាស់សម្រាប់តភ្ជាប់ឆ្អឹងដែលបែកបាក់។

**ក.១.៧ បន្ទប់ម៉ាស៊ីនត្រជាក់** គឺផ្អែកទៅតាមស្ថានភាពជាក់ស្តែង និង ការព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

**ក.១.៨ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះសម្រាប់របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព** គឺជាការបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ក្នុងករណីសង្គ្រោះបន្ទាន់ដោយរថយន្តសាមុយ(SAMU) ឬរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬ មធ្យោបាយផ្សេងៗទៀត ។ ការទូទាត់ថ្លៃសេវាបញ្ជូនត្រូវកំណត់ដោយប.ស.ស ផ្អែកទៅលើប្រភេទមធ្យោបាយបញ្ជូន និងទៅតាមតារាងតម្លៃសេវារបស់មូលដ្ឋានសុខាភិបាលសាធារណៈ ឬបន្ថែម៣០% (សាមសិបភាគរយ)ចំពោះប្រភេទមធ្យោបាយបញ្ជូនដោយរថយន្ត សាមុយ (SAMU) ឬ រថយន្តគិលានសង្គ្រោះ របស់មូលដ្ឋានសុខាភិបាលឯកជន ឬតាមមធ្យោបាយជាក់ស្តែង។

**ក.១.៩ ការបញ្ជូនសព** គឺជាការបញ្ជូនសពឬអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជាតាមគ្រប់ប្រភេទមធ្យោបាយបញ្ជូនពីកន្លែងគ្រោះថ្នាក់ ឬពី មូលដ្ឋានសុខាភិបាលទៅកាន់លំនៅស្ថានឬឈាបនដ្ឋានសម្រាប់ផ្នែកថែទាំសុខភាព។ ការទូទាត់ថ្លៃសេវាបញ្ជូនសពនេះផ្អែកតាមតម្លៃសេវាមូលដ្ឋានសុខាភិបាលសាធារណៈដែលបានផ្តល់សេវានោះឬផ្អែកទៅតាមតម្លៃកំណត់ដោយ

ប.ស.ស ដោយឈរលើស្ថានភាពទីតាំងភូមិសាស្ត្រ ចម្ងាយ និងប្រភេទមធ្យោបាយបញ្ជូន ។

**ក.១.១០ សេវាស្តារនីតិសម្បទា** គឺជាសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សម្រាប់ផ្នែកថែទាំសុខភាព ក្នុងគោលបំណងជួយដល់ជនរងគ្រោះ រក្សាស្តារ ឬធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទង ដែលបានបាត់បង់ ឬ ខូចខាតដោយសារជំងឺ រងរបួស ឬពិការភាព។ ការផ្តល់សេវាស្តារនីតិសម្បទា ឬសម្ភារៈបរិក្ខារ និងឧបករណ៍សិប្បនិម្មិត ឬ ត្រូវផ្តល់ទាំងអស់ហើយត្រូវកំណត់ជ្រើសរើស និង វាយតម្លៃដោយ ប.ស.ស ផ្អែកទៅលើស្ថានភាព និងតារាងតម្លៃសេវារបស់អង្គភាព ឬ ស្ថាប័នរដ្ឋ ឬ ឯកជនដែលផ្តល់សេវានោះ។

**ក.២ ករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធទី១**

**ក.២.១ ការចោះ ឬដាប់ឆ្អឹងលលាដ៍ក្បាល** (Trepanation) គឺជាអន្តរាគមន៍វះកាត់ដោយចោះ ឬ ដាប់ឆ្អឹងលលាដ៍ក្បាល ដើម្បីពិនិត្យស្រទាប់ក្រៅ នៃស្រោមខួរក្បាល និងព្យាបាល បញ្ហាសុខភាពទាក់ទង និងជំងឺក្នុងស្រទាប់ក្រៅនៃស្រោមខួរ និងក្នុងខួរក្បាល ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។

**ក.២.២ ការវះកាត់បេះដូងនិងសរសៃឈាម** គឺជាការវះកាត់បេះដូងនិងសរសៃឈាមធំៗដោយគ្រូពេទ្យឯកទេសវះកាត់បេះដូង ក្នុងករណីសង្គ្រោះបន្ទាន់សម្រាប់ផ្នែកថែទាំសុខភាព។ ចំពោះការវះកាត់បេះដូង និងសរសៃឈាមតាមការគ្រោងទុកមិនត្រូវបានរាប់បញ្ចូលឡើយ។

**ក.២.៣ ការព្យាបាលសង្គ្រោះបន្ទាន់ជំងឺបេះដូង** គឺជាអន្តរាគមន៍ព្យាបាល និងថែទាំវេជ្ជសាស្ត្រឯកទេសបេះដូងក្នុងគោលបំណងសង្គ្រោះអាយុជីវិតរបស់អ្នកជំងឺ ឬជនរងគ្រោះ សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព។

អន្តរាគមន៍នេះសម្រាប់តែមជ្ឈមណ្ឌលព្យាបាលជំងឺបេះដូងភ្នំពេញ ឬ មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងពិសេស ជាមួយបេឡាជាតិរបបសន្តិសុខសង្គមប៉ុណ្ណោះ ។

ខ. ប.ស.ស នឹងធ្វើការទូទាត់តាមប្រភេទសេវាសម្រាប់ករណី ក.១ និង ក.២ ដូចខាងក្រោម៖

ខ.១ សម្រាប់ប្រភេទករណីដូចមានចែងក្នុងចំណុច ក.១ នៃឧបសម្ព័ន្ធនេះ មូលដ្ឋានសុខាភិបាលនឹងទទួលបានការទូទាត់តាមប្រភេទសេវាសម្រាប់ថ្លៃសេវាពិសេសបន្ថែម ឬ សេវាព្យាបាល និងថៃទាំបន្តទៅតាមតម្លៃហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬ ទៅតាមការព្រមព្រៀង។ ការទូទាត់នេះមិនរាប់បញ្ចូលការទូទាត់តាមករណី ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១ ទេ។

ខ.២ សម្រាប់ករណីពិសេសដូចមានចែងក្នុងចំណុចក.២ នៃឧបសម្ព័ន្ធនេះមូលដ្ឋានសុខាភិបាល នឹងទទួលបានការទូទាត់ថ្លៃសេវាតាមប្រភេទសេវាហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬទៅតាមការព្រមព្រៀង។